# មជ្ឈមណ្ឌលឯកសារកម្ពុជា

គក ស្រល់ ភេទប្រុស (នៅរស់) K០៥៤៦២
មុខងារៈ អ្នកយាមមន្ទីរស-២១
ជួបជាមួយ គក ស្រល់ អាយុ៥៤ឆ្នាំ ជាម្ចាស់ប្រវត្តិរូប
រស់នៅភូមិលេខ៥ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល
នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤
សម្ភាសដោយៈ សារិន វីរៈ
សរុបៈ ៤៥ទំព័រ

វីរៈ ៈ អត់ទោសពូឈ្មោះអីដែរ?

ស្រល់ៈ គក ស្រល់ ។

វីរៈ ៈ គោកស្រល់ ។ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

ស្រល់ៈ ៥៤ ។

វីរៈ ៈ ពូកើតឆ្នាំខ្មែរត្រូវឆ្នាំអីគេដែរ?

ស្រល់ៈ ឆ្នាំថោះ ។

វីរៈ ៈ ប្រពន្ធពូឈ្មោះអីដែរ?

ស្រល់ៈ សុខ យៀវ ។

វីរៈ ៈ សុខ យៀវ ។ សព្វថ្ងៃគាត់អាយុប៉ុន្មានដែរ? មីងអាយុប៉ុន្មានហើយឆ្នាំហ្នឹង?

យៀវៈ ៥០គត់ ។

វីរៈ ៈ ៥០គត់ ។ មានកូនចៅប៉ុន្មាននាក់ហើយ?

ស្រល់ៈ ៥នាក់ ។

វីរៈ ៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ស្រល់ៈ ស្រីទាំងអស់ ។

វីរៈ ៈ កូន៥នាក់ ស្រីទាំងអស់ ។ សព្វថ្ងៃពូប្រកបមុខរបបធ្វើអីដែរ?

ស្រល់ៈ ធ្វើស្រែចំការ ។

យៀវៈ អត់មានចំការផង ធ្វើតែស្រែមួយមុខ ។

វីរះ ៖ ចុះមានជួញដូររកស៊ីអីដែរ?

ស្រល់ៈ អត់ ។

វីរះ ៖ ពូមានស្រុកកំណើតពូកើតហ្នឹងនៅឯណាដែរ?

ស្រល់ៈ នៅហ្នឹងហ្នឹង ។

វីរះ ៖ នៅហ្នឹងពីដើមគេហៅភូមិអីគេ?

ស្រល់ៈ ភូមិព្រែកតាទៀង ។

វីរះ ៖ ភូមិព្រែកតាទៀង ។

ស្រល់ៈ បាទ ពីដើមគេហៅព្រែកតាទៀង ។ ឥឡូវគេហៅភូមិព្រែកកុងយិន ។

វីរះ ៖ ឃុំអីគេដែរ?

ស្រល់ៈ ឃុំជ្រោយតាកែវ ។

វីរះ ៖ ស្រុក?

ស្រល់ៈ ស្រុកកោះធំ ខេត្តកណ្តាល ។

វីរះ ៖ ចុះសព្វថ្ងៃពូនៅហ្នឹងគេហៅភូមិអីគេ?

ស្រល់ៈ ភូមិលេខ៥ ។

វីរះ ៖ ឃុំដដែល?

ស្រល់ៈ ឃុំដដែល ។

វីរះ ៖ ឪពុកម្តាយរបស់ពូឈ្មោះអីដែរ?

ស្រល់ៈ ចក់ គក ។

វីរះ ៖ ចក់ គក ។ ចុះម្តាយ?

ស្រល់ៈ ម្តាយឈ្មោះ ហ៊ុន ឡូ ។

វីរះ ៖ ហ៊ុន ឡូ ។ គាត់ទាំងពីរសព្វថ្ងៃនៅដែរអត់?

ស្រល់ៈ ស្លាប់ ។

វីរះ ៖ គាត់ស្លាប់ជំនាន់ណាដែរ?

ស្រល់ៈ ស្លាប់ជំនាន់ប៉ុល ពត ។

វីរះ ៖ ហេតុអីបានគាត់ស្លាប់?

ស្រល់ៈ ត្រូវគ្រាប់ ។

វីរះ ៖ ត្រូវគ្រាប់ទាំងពីរនាក់?

ស្រល់៖ ត្រូវតែឪពុកទេ ម្ដាយនៅ ។

វីរះ ៖ ម្ដាយគាត់ស្លាប់ក្រោយបែក?

ស្រល់៖ នៅ ។ នៅមកដល់សព្វថ្ងៃ ។

វីរះ ៖ គាត់អាយុប៉ុន្មានហើយ ។

ស្រល់៖ អាយុ៧០ហើយ ។

វីរះ ៖ ចុះលោកតាគាត់ត្រូវគ្រាប់ហ្នឹងជាយោធាឬមួយយ៉ាងម៉េច?

ស្រល់៖ ប្រជាជនយើងហ្នឹង រត់....។

វីរះ ៖ រត់កាលឆ្នាំណា?

ស្រល់៖ រត់កាល៧០ សង្គ្រាមក្នុងភូមិហ្នឹង ។

វីរះ ៖ ពេលដែលរដ្ឋប្រហារលន់ នល់ហើយ?

ស្រល់៖ ពេលរដ្ឋប្រហារលន់ នល់ហ្នឹងហ្នង ។

វីរះ ៖ ត្រូវគ្រាប់របស់ខាងណា?

ស្រល់៖ ត្រូវគ្រាប់របស់ធីវគីផ្ទោងមក ។

វីរះ ៖ និយាយពួកធីវគីហ្នឹងទាហានខាងណា?

ស្រល់៖ ទាហានខាងលន់ នល់ ។

វីរះ ៖ កាលហ្នឹងពេលដែលរត់ហ្នឹងខាងធីវគីហើយមានទាហានវៀតណាមខាងណាផ្សេងទៀត?

ស្រល់៖ ទាហានយៀកកុងយើងហ្នឹង ។

វីរះ ៖ យៀកកុងហ្នឹងខាងខ្មែរក្រហម?

ស្រល់៖ ខាងខ្មែរក្រហម ។ យៀកកុងហ្នឹងយួនខាងជើង ខាងយួនផង ហើយធីវគីហ្នឹងក៏យួនដែរ ។

វីរះ ៖ មួយយួនជើង មួយយួនខាងត្បូង?

ស្រល់៖ បាទ វាមកចំរុះគ្នា ។ ខាងយួនខាងត្បូងក៏ចូល ខាងយួននេះក៏ចូលដែរ ព្រោះពួកយៀកកុងវានៅជុំវិញយើងទាំងអស់ ។

វីរះ ៖ ពេលហ្នឹងរត់ត្រូវគ្រាប់របស់ពួកធីវគីទេ មិនមែនរបស់ពួកខ្មែរក្រហមទេ?

ស្រល់៖ ហ្នឹងហើយត្រូវគ្រាប់ផ្ទោងរបស់ពួកធីវគី ។

វីរះ ៖ កាលហ្នឹងយ៉ាងម៉េចបានថាពួកហ្នឹងឈ្លោះគ្នា?

ស្រល់៖ ពួកហ្នឹងវាដណ្ដើមអំណាចគ្នា ពួកយៀកកុងចូលមកវ៉ៃពួកទាហានលន់ នល់ ដើម្បីយកទឹកដីវិញ ។

វីរះ ៈ នៅចាប់មានទាហានខាងយៀកកុងតាំងពីពេលណាមក? ខ្មែររំដោះអីហ្នឹង?

ស្រល់ៈ តាំងពីឆ្នាំ១៩៧០មករហូត ។

វីរះ ៈ ចុះមុន៧០ហ្នឹងកើតមានខ្វះនៅ?

ស្រល់ៈ អត់មាន ។ មុន៧០អត់មានពាក្យថាយៀកកុងអីទេ ។ ទល់តែរដ្ឋប្រហារឆ្នាំ៧០ហ្នឹងបានពុ ។

វីរះ ៈ ចុះធីវគី?

ស្រល់ៈ ធីវគីក៏ចឹងដូចគ្នាដែរ ។

វីរះ ៈ ខាងលន់ នល់ ពឹងឲ្យជួយ?

ស្រល់ៈ ពឹងឲ្យជួយ ។

វីរះ ៈ ហើយពួកខាងធីវគីហ្នឹងគ្នាច្រើនទេនៅក្នុងភូមិឃុំ?

ស្រល់ៈ អាហ្នឹងគេឡើងមកម្ដងៗ ។

វីរះ ៈ ចុះទាហានលន់ នល់ឆ្នាំ៧០មានពេញនៅហ្នឹងហើយ?

ស្រល់ៈ ហែហូររហូតតាមភូមិ ។

វីរះ ៈ គាត់ត្រូវគ្រាប់មកដូចថាពេលដែលរត់ហ្នឹងគ្រាប់ផ្លោងមកត្រូវស្លាប់ក្លាមហ្នងទៅ?

ស្រល់ៈ មិនទាន់ស្លាប់ទេ គាត់នៅ ត្រូវរបួស ប៉ុនមើលយូរៗទៅត្រូវស្លាប់ ។

វីរះ ៈ ចុះបងប្អូនបង្កើតរបស់ពូមានប៉ុន្មាននាក់ដែរ?

ស្រល់ៈ បងប្អូនបង្កើត៩នាក់ ។

វីរះ ៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ស្រល់ៈ ស្រី៤ ប្រុស៥ ។

វីរះ ៈ ចុះសព្វថ្ងៃនៅសល់ប៉ុន្មាននាក់ដែរគិតទាំងពូ?

ស្រល់ៈ អ្នកនៅរស់?

វីរះ ៈ បាទ នៅរស់ ។

ស្រល់ៈ នៅរស់៨នាក់ ស្លាប់១ ។

វីរះ ៈ មួយហ្នឹងទើបតែស្លាប់ឥឡូវ មិនមែនស្លាប់ពីជំនាន់មុនទេ?

ស្រល់ៈ អត់ទេ ទើបតែស្លាប់ទេ ។

វីរះ ៈ ចុះបងប្អូនពូចេញទៅធ្វើបដិវត្តជាមួយគ្នាអត់ទេកាលហ្នឹង?

ស្រល់ៈ ចេញទៅធ្វើទាំងអស់ ។

វីរះ ៈ ហើយបានត្រឡប់មកផ្ទះវិញទាំងអស់ដែរ?

ស្រលៈ មកផ្ទះវិញទាំងអស់ ។

វីរៈ ៖ អត់មានបាត់ទេ?

ស្រលៈ អត់ ។

វីរៈ ៖ ចុះជីដូនមួយអី? សាច់ឆ្ងាយអីមានបាត់ទេ?

ស្រលៈ ជីដូនមួយអីមានបាត់ខ្លះ ។

វីរៈ ៖ បាត់ដែរ ។ ឈ្មោះអីទៅ?

ស្រលៈ បាត់ឈ្មោះផាត ឈ្មោះប្រុក ។

វីរៈ ៖ គាត់ហ្នឹងចេញទៅធ្វើអីដែរ?

ស្រលៈ ចេញទៅធ្វើបដិវត្តដូចគ្នាចឹង ។

វីរៈ ៖ យោធា?

ស្រលៈ ចេញទៅធ្វើយោធាដូចគ្នា ។

វីរៈ ៖ កាលពេលមុនពូចេញទៅពូមានបានរៀនសូត្រអីអត់ទេកាលនៅស្រុកភូមិ?

ស្រលៈ មុនចេញទៅហ្នឹងនៅរៀនសូត្រតាមភូមិតាមឃុំហ្នឹង ។ ពង្រឹងផ្នែកនយោបាយអីហើយ បាន ចេញពីភូមិឃុំទៅ ។

វីរៈ ៖ ចឹងមុនចេញពីភូមិឃុំទៅគេបង្រៀននយោបាយដល់យើងដែរ?

ស្រលៈ បង្រៀន ។

វីរៈ ៖ ឆ្នាំណាបង្រៀននយោបាយហ្នឹង?

ស្រលៈ បង្រៀនតាមថ្នាក់ហែហូរហូតហ្នឹង អត់មានកំណត់ថាអ្នកណាៗទេ ។

វីរៈ ៖ ក្នុងថ្នាក់ហ្នឹងប្រជាជនរៀនទូទៅ ឬក៏មានរៀនតែពួកខាងបុរសៗ?

ស្រលៈ ខាងផ្នែកយុទ្ធជនហ្នងអាហ្នឹង ។

វីរៈ ៖ យុទ្ធជន ។

ស្រលៈ សុទ្ធតែយុទ្ធជនហ្នឹង ។ឧបមាថាយុទ្ធជនចេញទៅចូលទៅក្នុងភូមិប្រហែលសាមសែសិបនាក់ ហ្នឹង គេបង្រៀនចឹងទៅ ។ ដល់នៅរៀនជាមួយគេយូរៗទៅ បានគេបញ្ជូនឡើងតទៅទៀត ។

វីរៈ ៖ ពេលបង្រៀនហ្នឹងគេនិយាយពីអីខ្លះទៅ?

ស្រលៈ រៀនផ្នែកនយោបាយហ្នឹង ។

វីរៈ ៖ នយោបាយហ្នឹងគេចង់និយាយថាម៉េច? សំដៅទៅលើអីថាឲ្យយើងយ៉ាងម៉េច?

ស្រលៈ គេច្រើនទែតរៀននយោបាយខាងម៉ាក លេនីន ។

វីរះ ៖ ម៉ាក លេនីន ។ ពូនៅចាំបានទេថាគេប្រកាន់យកគំនិតម៉ាក លេនីនហ្នឹងគេចង់សំដៅទៅលើអី គេ និយាយពីនយោបាយហ្នឹង ការគ្រប់គ្រងឬមួយវាយ៉ាងម៉េច?

ស្រល់៖ គេនិយាយពីការបំផុសបំផុលឲ្យយើងយល់ច្បាស់ពីបញ្ហានយោបាយហ្នឹង ដើម្បីឲ្យឈឺចាប់ពីការជិះជាន់របស់យើងពីសង្គមមុន ។

វីរះ ៖ ឲ្យយើងដើរតាមនយោបាយរបស់លេនីន?

ស្រល់៖ បាទ ។

វីរះ ៖ ពូមានចាំទេថាពូចាប់ផ្ដើមរៀននយោបាយតាំងពីឆ្នាំណាមក?

ស្រល់៖ នយោបាយរៀនតាំងពីឆ្នាំ៧៣មករហូត ។

វីរះ ៖ ៧៣ ។ ចុះមុន៧៣ហ្នឹង?

ស្រល់៖ មុន៧៣ហ្នឹង នៅប្រទាញប្រទង់គ្នាជាមួយយៀកកុង និងខ្មែររំដោះយើង ។

វីរះ ៖ កាលហ្នឹងពូធ្វើយោធាហើយឬនៅ?

ស្រល់៖ កាលហ្នឹងនៅទេ ខ្ញុំនៅភូមិ នៅផ្ទះទេ ។

វីរះ ៖ នៅធ្វើអីគេ?

ស្រល់៖ នៅធ្វើស្រែចំការធម្មតាជាមួយឪពុកម្ដាយហ្នឹង ។ នៅក្រោមរូង ហើយកាលហ្នឹងពាក់ព័ន្ធជាមួយពួកយៀកកុងឡើងទៅ ហើយខ្មែរយើងត្រូវបាក់បែកគ្នាទៅវិញ ។

វីរះ ៖ ពូចាំទេថាកាលរៀនវគ្គនយោបាយអី តើមានគំនិតដឹកនាំពីអ្នកណាគេមកដែលចាប់ផ្ដើមឲ្យប្រមូលយុទ្ធជនទៅរៀននយោបាយអីហ្នឹង?

ស្រល់៖ ការប្រមែលប្រមូលដឹកនាំមក និងការប្រមែលប្រមូលទៅហ្នឹង បញ្ហាហ្នឹងអត់មានថាចោទទៅលើបុគ្គលណាម្នាក់ៗអត់ គេនិយាយតែរឿងអង្គការហ្នុង ។ គេនិយាយថាអង្គការឲ្យប្រមែលប្រមូល មិនដឹងអង្គការមួយណា បើវាទូទៅទាំងអស់ហ្នឹង ។

វីរះ ៖ ពេលដែលចាប់ផ្ដើមប្រមូលឲ្យរៀនហ្នឹងគេដើរប្រកាសតាមភូមិ តាមស្រុកហ្នុងថាឥឡូវយុទ្ធជនទាំងអស់ចូលសិក្សានយោបាយចឹង ឬមួយចូលតាមខ្សែរ ឬមួយយ៉ាងម៉េច?

ស្រល់៖ អាហ្នឹងគេមកគ្រាន់តែប្រាប់យើងតាមភូមិ ។ ឃុំគេប្រាប់ភូមិ ភូមិគេដើរប្រាប់យើងគ្រប់គ្នាចឹងទៅ គេដើរហៅ ។

វីរះ ៖ កន្លែងដែលរៀនហ្នឹងឈ្មោះអីនៅម្ដុំណាដែរ?

ស្រល់៖ នេះនៅខាងជើង ។

វីរះ ៖ គេហៅអីដែរកន្លែងហ្នឹង?

ស្រល់ៈ កន្លែងហ្នឹងគេហៅមន្ទីរពេទ្យហើយឥឡូវ នៅត្រពាំងស្រុកថៃ ។

វីរៈ ៈ នៅឃុំណា?

ស្រល់ៈ ឃុំលេខ២ ប៉ុនបើហៅចូលទៅគឺនៅហ្នឹងហើយអត់មានមកផ្ទះវិញទេ ។ នៅមូលគ្នានៅហ្នឹងទាំងអស់ ។

វីរៈ ៈ ទាំងព្រឹកទាំងល្ងាចរហូតទៅ?

ស្រល់ៈ នៅមូលគ្នាហ្នឹង បាយទឹកនៅហ្នឹងរហូតទៅ បើហៅទៅគឺនៅរហូតអត់មានមកផ្ទះវិញទេ ។ គ្រាន់តែថាពេលណាសម្រាកចឹងយើងសុំគេមកលេងផ្ទះ ។

វីរៈ ៈ គេឲ្យមកដែរ?

ស្រល់ៈ គេឲ្យមក ។

វីរៈ ៈ មករាល់ថ្ងៃ?

ស្រល់ៈ មិនមែនរាល់ថ្ងៃទេ យូរៗមកម្តងចឹងទៅ ។

វីរៈ ៈ កាលនៅរៀនហ្នឹងពូនៅរយៈពេលប៉ុន្មានដែរ?

ស្រល់ៈ នៅមិនទៀង ។ ជួនកាលនៅបានមួយខែ ជួនកាលនៅបានពីរខែចឹងទៅ ហើយអង្គការលើត្រូវការជ្រើសរើសទ័ពមកទៀត យើងអ្នកទៅរៀនហ្នឹងគេរើសយកទៅបណ្តោយ ។

វីរៈ ៈ ចុះពូផ្ទាល់ កាលហ្នឹងរៀនបានរយៈពេលប៉ុន្មានខែ បើតាមពូស្មានៗ?

ស្រល់ៈ ខ្ញុំនៅប្រហែលជា២ខែកន្លះ ឡើងទៅបណ្តោយទៅ ។

វីរៈ ៈ ២ខែកន្លះពូឡើងទៅ ហើយមួយជំនាន់ពូហ្នឹងមានគ្នាប្រហែលប៉ុន្មានទៅ?

ស្រល់ៈ ខ្ញុំឡើងពីឃុំទៅ៣០នាក់ ។

វីរៈ ៈ ពីខាងឃុំយើងនេះ?

ស្រល់ៈ ហ្នឹងហើយ ។ ទៅមូលគ្នានៅ.... ។

វីរៈ ៈ ឃុំលេខ២ហ្នឹង?

ស្រល់ៈ អត់ទេ អាហ្នឹងចេញពីឃុំលេខ២ទៅ ចូលទៅសាលាយោធាគេមួយទៀត ។ ពេលចូលសាលាយោធាហ្នឹងសម្រុកគ្នាច្រើនហ្មង គេក៏ចូលយើងក៏ចូលជាមួយគ្នាច្រើនណាស់ ។ ទៅរៀននៅសាលាយោធានៅកំពតពុលហ្នឹងទៀត ។

វីរៈ ៈ សាលាយោធានៅកំពតពុល?

ស្រល់ៈ បាទ នៅវត្តកំពតពុលហ្នឹងទៀត ។

វីរៈ ៈ វត្តកំពតពុលនៅក្នុងស្រុកអីដែរ?

ស្រលះ អាហ្នឹងនៅស្រុកស្អាង ។

វីរះ : ឃុំអីគេ?

ស្រលះ មិនដឹងឃុំអីទេ កន្លែងហ្នឹងព្រែកអំបិល គេហៅស្រុកស្អាង ។

វីរះ : នៅឃុំព្រែកអំបិល?

ស្រលះ ស្អាងព្រែកអំបិល ។

វីរះ : សាលាឃោឃាគេនៅហ្នឹងហ្នុង?

ស្រលះ សាលាឃោឃាគេនៅហ្នឹង ទៅដល់មូលគ្នានៅហ្នឹងទាំងអស់គ្នា ។

វីរះ : ខ្ញុំបកទៅក្រោយបន្តិចត្រង់ពូថាពីឃុំប្រាប់មកភូមិ ពីភូមិប្រាប់មកពូឲ្យទៅរៀននយោបាយ ។ កាលហ្នឹងប្រធានភូមិឈ្មោះអីដែរ? ពូមានចាំទេ ។

ស្រលះ អុំដៃ ។

វីរះ : ដៃ ។ គាត់ស្លាប់ហើយ?

ស្រលះ ស្លាប់ហើយ ។

វីរះ : ថីបានគាត់ស្លាប់?

ស្រលះ ឈឺស្លាប់ ។

វីរះ : ទើបតែឥឡូវៗហ្នឹងទេ?

ស្រលះ យូរហើយ ។

វីរះ : ប៉ុនបែកហើយ?

ស្រលះ បែកហើយបានស្លាប់ ។

វីរះ : ចុះគណៈឃុំ?

ស្រលះ ពូដាង ប៉ុនគាត់ស្លាប់អស់ហើយ ។

វីរះ : គាត់ទើបតែស្លាប់ឥឡូវហ្នឹងដែរ ឬស្លាប់ពីជំនាន់ប៉ុល ពតមក?

ស្រលះ បែកហើយបានស្លាប់ ។

វីរះ : ចុះឃុំហ្នឹងទទួលពីស្រុកមកទៀតបានឲ្យយើងទៅរៀន ។

ស្រលះ ទទួលពីលើមកទៀត មកពីស្រុកមក ។

វីរះ : ស្រុកអីគេ?

ស្រលះ ស្រុកកោះធំ ។

វីរះ : គេមានដាក់លេខទេ?

ស្រល់៖ ស្រុក១៣ ។ ចែកលេខចែកឃុំអាពតហ្នឹងហើយ ។

វីរះ ៖ ពូស្គាល់ទេឈ្មោះគណៈស្រុកហ្នឹង?

ស្រល់៖ អត់ស្គាល់ទេ ឡើងទៅលើឆ្ងាយពេកខ្ញុំអត់ស្គាល់ទេ ។

វីរះ ៖ ពេលដែលពូទៅរៀននយោបាយ នៅឃុំលេខ២ហ្នឹង គេរៀនសូត្រមួយថ្ងៃរៀនប៉ុន្មានម៉ោង?

ស្រល់៖ មួយពេលៗ រៀន២ម៉ោង ។

វីរះ ៖ ព្រឹកល្ងាចអត់ទេ ឬក៏រៀនមួយពេលៗ?

ស្រល់៖ មួយពេលៗ ពេលល្ងាច ។

វីរះ ៖ ចប់រៀនធ្វើអីទៀត?

ស្រល់៖ ចប់រៀនទៅធ្វើការងារតាមកន្លែងក្រសួងយើងនៅ ។

វីរះ ៖ ពេលនៅរៀននយោបាយរយះពេល២ខែកន្លះហ្នឹង?

ស្រល់៖ ហ្នឹងហើយ ។ រៀនតែថ្ងៃល្ងាចៗចឹងរយះពេល២ម៉ោង បើខុសម៉ោងហ្នឹងយើងទៅធ្វើការធម្មតា ។ នៅក្នុងអង្គភាពហ្នឹងមានធ្វើស្រែធ្វើចំការដែរ ។ ចឹងយើងរៀនតែ២ម៉ោងហ្នឹងទេ ហើយផុតពីហ្នឹងយើងទៅស្ទូងស្រូវ ធ្វើស្រែជាមួយគេជាមួយឯងមក ។

វីរះ ៖ ពូនៅចាំអ្នកដឹកនាំនៅកន្លែងសាលានយោបាយហ្នឹងឈ្មោះអីដែរ?

ស្រល់៖ នៅឃុំហ្នឹង?

វីរះ ៖ ពូទៅរៀនរយះពេល២ខែកន្លះហ្នឹងខាងឃុំគេអ្នកបង្រៀន ឬខាងណាអ្នកបង្រៀន?

ស្រល់៖ បងអ៊ិន ។

វីរះ ៖ ឈ្មោះអ៊ិនហ្នឹងគាត់តួនាទីធ្វើអីដែរ?

ស្រល់៖ គាត់ធ្វើប្រធានយុទ្ធជននៅឃុំ ។

វីរះ ៖ ចឹងគាត់ជាអ្នកបង្រៀននយោបាយហ្នុង?

ស្រល់៖ គាត់អ្នកបង្រៀន ។

វីរះ ៖ អ៊ិន ហ្នឹងគាត់មកពីខាងណាដែរ?

ស្រល់៖ អ៊ិននៅជាមួយគ្នា ។

វីរះ ៖ នៅស្រុកភូមិអីជាមួយគ្នា?

ស្រល់៖ នៅស្រុកភូមិជាមួយគ្នា ។

វីរះ ៖ អ្នកណាគេអ្នកចាត់តាំងឲ្យគាត់ធ្វើជាប្រធានយុទ្ធជននៅឃុំហ្នឹង?

ស្រល់៖ គេចាត់តាំងមកពីលើដូចតែគ្នាហ្នឹង នៅភូមិគ្មានអ្នកណាមានសិទ្ធចាត់តាំងបានទេ ទាល់តែមកពីស្រុកអីចាត់តាំងមកឃុំ បើក្នុងឃុំចាត់អត់បានទេ ។

វីរះ ៖ ពេលពូចូលទៅដល់ឃើញគាត់ហើយ?

ស្រល់៖ គាត់នៅហើយ ។

វីរះ ៖ គាត់ត្រកូលអី?

ស្រល់៖ អត់ដឹង ។

វីរះ ៖ ចុះសព្វថ្ងៃគាត់នៅទេ?

ស្រល់៖ ស្លាប់បាត់ហើយ ។

វីរះ ៖ រយះពេល២ខែកន្លះហ្នឹងមានគ្នាប៉ុន្មាននាក់ជំនាន់ពូ? ៣០នាក់?

ស្រល់៖ ៣០នាក់ ។

វីរះ ៖ មានមកពីខាងឃុំគេផ្សេងទេ ឬតែមួយឃុំយើង?

ស្រល់៖ តែឃុំយើងទេ ។ យើងមួយឃុំហ្នុង ។

វីរះ ៖ ពូអាចលំអិតបានទេថាកាលរៀនហ្នឹងមួយពេលៗគេនិយាយពីអីខ្លះ?

ស្រល់៖ ភ្លេចអស់ហើយ យូរៗហើយ ។

វីរះ ៖ តែទាក់ទងតែរឿងលទ្ធិម៉ាក លេនីនហ្នឹងហ៎?

ស្រល់៖ បាទ!

វីរះ ៖ ចប់រយះពេល២ខែកន្លះ ឈ្មោះអ៊ិនផ្ទាល់ឬមួយក៏មានអ្នកណាផ្សេងទៀតដែលបញ្ជូនទៅខាងសាលាយោធាហ្នឹង?

ស្រល់៖ អាហ្នឹងបញ្ជាមកពីថ្នាក់លើទេ បែបមកពីស្រុកមកដូចថាគេត្រូវការខ្លះទ័ពប៉ុន្មាន ដូចថាគេខ្វះទ័ព៥០ចឹងទៅគេយកពីឃុំយើងជ្រោយតាកែវហ្នឹងណា យកប៉ុន្មានថា២០នាក់ចឹងទៅ យកពីឃុំអំពិលពោធិ៍ប៉ុន្មាននាក់ទៀត យកឃុំនេះប៉ុន្មាននាក់ទៀតទៅ ។ យកទៅគម្រប់នៅកន្លែងហ្នឹងហ្នុង ។ ដល់ស្រុកបួនទៅឡើងយកទៅឲ្យគេ ។ គេមិនយកតែមួយឃុំទេ ។

វីរះ ៖ សាលាយោធាហ្នឹងសម្រាប់ស្រុក ឬឃុំ?

ស្រល់៖ ពេលឡើងទៅលើទៅអាហ្នឹងសម្រាប់ស្រុកហើយ ។ ចេញពីឃុំទៅអាហ្នឹងសម្រាប់ចូលស្រុក ។ ដល់គេតម្រូវការដូចថា២០០នាក់ចឹង ដើរប្រមូលតាមឃុំដល់ស្រុកបាន២០០ បានបញ្ជូនទៅសាលានយោបាយតទៅទៀត ។

វីរះ ៖ សាលាយោធាហ្នឹង?

ស្រល់៖ បាទ ៗ ដល់ទៅនោះគេចែកហើយ ដូចថាក្រុមណាខ្លះប៉ុន្មាន ក្រុមណាខ្លះប៉ុន្មានគេឲ្យទៅតាមហ្នឹងហើយដាក់គ្រប់ចំនួនក្រុមទៅ ។ មួយក្រុម១២នាក់ដាក់ឲ្យពេញៗទៅ ចូលទៅធ្វើទ័ពទៅ ។

វីរៈ ៖ ចឹងនៅស្អាងគេហៅសាលាយោធាចឹងហ្នង?

ស្រល់៖ ហ្នឹងហើយ ។

វីរៈ ៖ ចុះអ្នកណាគេមេសាលាហ្នឹង?

ស្រល់៖ អត់ចាំទេ ចំរុះគ្នាច្រើនពេក ។

វីរៈ ៖ នៅហ្នឹងគេបែងចែកជាវីរៈអីអត់ទេ?

ស្រល់៖ នៅកន្លែងហ្នឹងពេលរៀនចឹងគេមិនទាន់បែងចែកទេ ដល់រៀនហើយបានគេបែងចែកចេញ ។

វីរៈ ៖ រៀនអីគេ?

ស្រល់៖ រៀនផ្នែកយោធាហ្នង ខាងបាញ់ ខាងលូន ខាងក្រាបហ្នឹង ។

វីរៈ ៖ រៀនយោធាហ្នឹងបានរយៈពេលប៉ុន្មាន?

ស្រល់៖ ទៅរៀនហ្នឹងបានរយៈពេលមួយខែ ។

វីរៈ ៖ ឆ្នាំប៉ុន្មានទៅ? ប្រហែលជាឆ្នាំណា?

ស្រល់៖ រយៈពេលមួយខែខ្ញុំនៅឆ្នាំ៧៤ ។

វីរៈ ៖ ដើមឆ្នាំ ឬចុងឆ្នាំ?

ស្រល់៖ ចុងឆ្នាំហើយ ។

វីរៈ ៖ រយៈពេលមួយខែហ្នឹងគេរៀនពីអីខ្លះ ដូចថាលូន?

ស្រល់៖ យើងកាន់គ្រឿងសឹក កាន់កាំភ្លើងកាន់អីហ្នឹង ។

វីរៈ ៖ មានបាញ់អីទេ សមបាញ់ផ្ទាល់ដែរហ្អី?

ស្រល់៖ បាញ់អត់មានទេ តែរៀនច្រើនអត់បាញ់ទេ ។ កាំភ្លើងកាន់ត្រឹមត្រូវដូចគ្នា ប៉ុនដល់រៀនវ៉ៃគេអត់ហ៊ានឲ្យយើងបាញ់ទេ ខ្លាចគ្រោះថ្នាក់ ។ គេប្រើតែដុំដីទេ ។

វីរៈ ៖ កាលហ្នឹងអ្នកដែលបង្រៀនពូហ្នឹងពូចាំទេ?

ស្រល់៖ អត់ចាំទេ ច្រើនគ្នា ។

វីរៈ ៖ ឥឡូវដូចថារយៈពេលមួយខែដែររៀនហ្នឹងយុទ្ធជនទាំងអស់រៀនរួមគ្នាហ្នង ឬគេបែងចែកជាផ្នែកៗ ហើយមានការមើលខុសត្រូវម្នាក់ៗ?

ស្រល់៖ អាហ្នឹងដូចថាគេចែកជាកង៥០ ។

វីរៈ ៖ មួយកង៥០ៗ?

ស្រលៈ មួយកង៥០ចឹងទៅ មួយកង៥០ៗមេមួយចឹងហ្នឹង អត់មានយកទៅសំលាប់គ្នាច្រើនទេ ។
វីរៈ ៖ មួយកង៥០គ្នាប្រហែលប៉ុន្មាន?
ស្រលៈ ៥០នាក់ ។
វីរៈ ៖ ប៉ុន្មានកង៥០នៅកន្លែងហ្នឹងពូអាចស្មាន?
ស្រលៈ មានច្រើន គ្នារាប់ពាន់អ្នកណោះ ។
វីរៈ ៖ មានប្រធានមួយ មួយកង៥០ចឹង?
ស្រលៈ ប្រធានមួយ ។
វីរៈ ៖ ចុះប្រធានកង៥០របស់ពូឈ្មោះអី?
ស្រលៈ ភ្លេចអស់ហើយ ។
វីរៈ ៖ គាត់អ្នកស្រុកភូមិហ្នឹងដែរ?
ស្រលៈ អត់ទេ មិនដឹងមកពីណា រើសចេញពីទ័ពហ្នឹងមក គេអ្នកខ្លាំងៗមកគេអ្នកចេះខ្លាំងៗ មកបង្ហាត់យើង ។
វីរៈ ៖ អត់ចាំឈ្មោះទេពូ?
ស្រលៈ អត់ចាំ ។
វីរៈ ៖ ចុះកងគេផ្សេងពូមានចាំអ្នកណាគេទេ?
ស្រលៈ ភ្លេចអស់ហើយ បើរយះ៥-៦ឆ្នាំយើងនៅចាំខ្លះ តែនេះវាយូរយាហើយ ។
វីរៈ ៖ ចុះពេលរៀនរយះពេលមួយខែមានដែលឃើញអ្នកធំៗនៅខាងតំបន់អីគេចុះមកមើលទេ?
ស្រលៈ គេមក គេខស្សប្តាហ៍មកចឹងអីហើយហ្នឹង ។
វីរៈ ៖ គេមកដែរ ។ មានត្រឹមថ្នាក់ណាខ្លះ?
ស្រលៈ មានតាំងពីខាងកងពលហ្នឹងក៏មកដែរ?
វីរៈ ៖ កងពលហ្នឹងអ្នកណាគេ តាណាតហ្នឹងមែន?
ស្រលៈ តាណាត តាពីន គាត់មកមើលសាលា ។
វីរៈ ៖ ចុះមកផ្ទាល់?
ស្រលៈ ចុះមកផ្ទាល់ៗ មកមើលផ្ទាល់ហ្នឹង ។
វីរៈ ៖ ចុះក្រៅពីគាត់ពីរនាក់ហ្នឹងមានអ្នកណាផ្សេងទៀត?
ស្រលៈ គេបន្តបន្ទាប់ហ្នឹងមកហែហូរ ឲ្យតែនៅក្នុងកងពល៧០៣ហ្នឹងគេចុះមកមើលទាហានហាត់ ។
វីរៈ ៖ ខស្សប្តាហ៍មកទេ ក្នុងមួយខែពូឃើញគាត់មកប៉ុន្មានដង?

ស្រល់៖ អ្នកធំគេមកចែកថ្ងៃគ្នា មួយខែមកម្ដង ក្រោពីហ្នឹងថ្នាក់តូចៗមកហែហូរជាប់មករហូត ។

វីរះ ៖ ថ្នាក់តូចៗថ្នាក់ត្រឹមណា?

ស្រល់៖ ថ្នាក់វីរសេនាធំអីវិន ។

វីរះ ៖ អត់មានចាំឈ្មោះខ្លះទេ?

ស្រល់៖ អត់ ។

វីរះ ៖ រយះពេលបានមួយខែកន្លះហ្នឹងដូចថាគេចាប់ផ្ដើមបំបែកនាំយើងទៅ?

ស្រល់៖ ចេញទៅទ័ពហើយ ទៅវៃហើយ ទៅទាហានចំហើយអត់មាននៅរៀននៅណាទៀតទេ ។

វីរះ ៖ ទៅវៃហ្នឹង ប្រុងទៅវៃរំដោះយកភ្នំពេញ?

ស្រល់៖ វៃរំដោះយកភ្នំពេញហ្នុង ។

វីរះ ៖ ពេលដែលពូចេញពីហឹងប្រហែលចូល៧៥ហើយឬនៅ?

ស្រល់៖ ចេញពីហ្នឹងទៅចូល៧៥ ។

វីរះ ៖ ចេញក្វាមទៅណាទៅ?

ស្រល់៖ ចេញក្វាមឡើងបណ្ដោយ ចេញទៅភ្នំពេញ ។

វីរះ ៖ វៃតាមណា?

ស្រល់៖ វៃតាមផ្លូវ២១ឡើងទៅ ។

វីរះ ៖ គេបែងចែកជាកងជាវីរៈជាអី?

ស្រល់៖ ហ្នឹងហើយអាហ្នឹងចូលទៅក្រុមនៅវីរសេនាតូច ។ ស្រាប់តែទៅវីរសេនាតូចពេញចឹងទៅ
ឡើងទៅវៃរហូតហ្នុង វៃចូលទៅដល់ភ្នំពេញ ។

វីរះ ៖ វីរសេនាតូចលេខប៉ុន្មានពូកាលហ្នឹង?

ស្រល់៖ នៅវីរសេនាតូច១៣៨ ។

វីរះ ៖ គេបញ្ជូនពូទៅវីរសេនាតូច១៣៨?

ស្រល់៖ ...........

វីរះ ៖ ម៉េញពូមានប្រសាសន៍ថាទៅវៃតាមច្រកណាម៉េញ?

ស្រល់៖ វៃតាមផ្លូវជាតិយើង២១ឡើងទៅ ។ ទៅបុកទៅភ្នំពេញហ្នុង ។

វីរះ ៖ ពូបានចូលទៅដល់ភ្នំពេញដែរ?

ស្រល់៖ ចូលទៅ ទៅនៅណោះបណ្ដោយ ។

វីរះ ៖ កាលហ្នឹងគេបែងចែកដូចថាមួយកងពលហ្នឹងមានប៉ុន្មានវីរៈទៅវីរសេនាធំ? មួយខាងយើង ខាងភាគតំបន់នេះបែងចែកគ្នាយ៉ាងម៉េច?

ស្រល់៖ អាហ្នឹងវាតាមមុខសញ្ញារៀងខ្លួនកងពលដូចថា៧០៣ អាហ្នឹងគឺកងពល៧០៣ចឹងវ៉ៃចូលទៅ ហើយបើកងពល៥០២គេវ៉ៃពីលិចមក មុខសញ្ញាគេដឹងទែពីលិចទេ វ៉ៃចូលដូចគ្នា ។

វីរះ ៖ ៥០២មកពីខាងលិច?

ស្រល់៖ ហ្នឹងហើយ ។ ឧបមាថាគេវ៉ៃចឹងគេចែកមុខសញ្ញាគ្នាចឹង ។

វីរះ ៖ ចុះកាលហ្នឹងពូចាំទេវ៉ៃចូលមកប៉ុន្មានជ្រុងបានទៅដល់ភ្នំពេញ? ដូចថាកងពល៧០៣មួយ?

ស្រល់៖ វាពិបាកណាស់ ជួនកាលកងពលខ្លះចូលអត់ដល់ភ្នំពេញផង ។ ជួនកាលគេលឿនដាង គេចូលដល់ភ្នំពេញមុនឈ្នះទៅ ឯងនៅឯណានោះទៅ ។ អត់ទៀងទេរឿងវ៉ៃ ខាងណាវ៉ៃវាងផ្លូវដាង អាហ្នឹងលឿនដាងទៅ ។

វីរះ ៖ តែកាលហ្នឹងកងពលពូចូលទៅដល់ភ្នំពេញមុនគេឬយ៉ាងម៉េច?

ស្រល់៖ ចូលទៅមុនគេ៧០៣ ។

វីរះ ៖ ហើយដណ្ដើមបានគ្រប់គ្រងនៅភ្នំពេញបានមុនគេ?

ស្រល់៖ ទៅមុនគេចឹងទៅដល់យើងចាត់ចែងទៅ ដល់នេះអង្គការលើជួបជុំគ្នាត្រូវកងពលណាដកចេញដើម្បីទៅត្រៀមកន្លែងណាៗចឹង ។ ហ្នឹងចែកកងពលការពារ ។ ៧០៣គេចូលទៅមុនឲ្យការពារទីក្រុងទៅ ៥០២មកដល់ក្រោយចឹងទៅថាកងពលហ្នឹងមកដល់ក្រោយគេឥឡូវឲ្យដកទៅការពារខ្សែក្រវ៉ាត់ជុំវិញចេះ ។ គេចែកជាប្រចកៗគ្នាចឹង ។ ហើយកងពលខ្លះចូលមកដល់អស់គ្នាវាត្រូវមុខសញ្ញាគេ គេឲ្យទៅព្រំដែនវិញទៅ ។

វីរះ ៖ ទៅព្រំដែនធ្វើអី?

ស្រល់៖ ទៅការណារព្រំដែន ព្រោះយើងវ៉ៃឡើងចូលមកអីចេះអស់ហើយ អត់មានអ្នកណានៅក្រោយ អត់មានទេព្រំដែន ។ ចឹងគេចាត់ចែងឲ្យទៅនេះទៅនោះភ្លាម ។

វីរះ ៖ ម៉េញពូថានៅ១៣៨ហ្នឹងវីរសេនាតូច?

ស្រល់៖ វីរសេនាតូច ។

វីរះ ៖ ចង់សួរពូថាប្រធានវីរសេនាតូចរបស់ពូឈ្មោះអីដែរ?

ស្រល់៖ ឈ្មោះខន ។

វីរះ ៖ អីគេខន?

ស្រល់៖ មិនដឹងត្រកូលគាត់ទេ ស្គាល់តែឈ្មោះគាត់ ។

វីរះ ៖ ខនហ្នឹងដឹកនាំវ៉ៃផ្ទាល់?

ស្រល់៖ គាត់ជាបញ្ជាការ ។

វីរះ ៖ ចុះមានប៉ុន្មានវីរសេនាតូចដែរមួយវីរៈសេនាធំហ្នឹង?

ស្រល់៖ មួយវីរៈធំមាន ៣វីរសេនាតូច ។

វីរះ ៖ ចុះអ្នកណាគេប្រធានវីរសេនាធំពូហ្នឹង?

ស្រល់៖ អត់ចាំទេ ។ ចាំតែប្រធានកងពលតែតាណាគ និង តាពីន ។

វីរះ ៖ មួយកងពលមានប៉ុន្មានវីរសេនាធំ?

ស្រល់៖ មាន៣វីរសេនាធំ ។

វីរះ ៖ អត់មានចាំខ្វះទេអ្នកដែលមេៗវីរៈៗហ្នឹង?

ស្រល់៖ អត់ទេ ។ ចេះចាត់ឯណាដោយខ្លួន ដល់ហើយចាំបានតែប្រធានវីរៈខ្លួនឯង ។

វីរះ ៖ ចាំបានតែគាត់មួយហ្នឹង?

ស្រល់៖ បាទ!

វីរះ ៖ នៅក្នុងវីរសេនាតូចគេមានបែងចែកជាអីផ្សេងៗទៀតទេ?

ស្រល់៖ នៅក្នុងវីរសេនាតូចគេបែងចែកទៅជាកងរយទៀត ។

វីរះ ៖ កងរយ? កងហាទៀត?

ស្រល់៖ ហ្នឹងហើយ ។ ដូចវីរសេនាតូចចឹងគេបែងចែកជាបីកងរយ ។

វីរះ ៖ ចឹងគេបែងចែកជា៣ៗរហូត?

ស្រល់៖ ៣រហូត ។

វីរះ ៖ បើគិតទៅវីរសេនាតូចរបស់ពូគ្នាប្រហែលជាប៉ុន្មាននាក់?

ស្រល់៖ មួយវីរសេនាតូចគ្នាប្រហែលជា៣៥០នាក់ ។

វីរះ ៖ ៣៥០នាក់ ។ ចឹងមួយកងពលចូលរាប់ពាន់នាក់ហើយ?

ស្រល់៖ រាប់ពាន់ ។

វីរះ ៖ ពូគិតថាការដែលឈ្នះទៅលើទាហានលន់ នល់ហ្នឹង ដោយសារមូលហេតុអីបានខ្មែរក្រហមវ៉ៃបានដណ្ដើមបាន? ពូអាចយល់បានទេ តាមការដែលពូទៅវ៉ៃផ្ទាល់ចឹង ។

ស្រល់៖ អាហ្នឹងវានៅលើកំលាំងយើងច្រើន ដល់កំលាំងទ័ពខាងរំដោះច្រើនចឹងទៅដល់យើងវ៉ៃយើងមានប្រៀបដាងវាត្រូវកំលាំងតិច យើងដាក់ទៅ ចាញ់យើងបណ្ដោយទៅ ។

វីរះ ៖ មានខាងវៀតណាមមានអីទេកាលហ្នឹង?

ស្រស់: អត់មានទេ ។

វីរះ : លែងមានហើយ? ខាងលន់ នល់ លែងឲ្យខាងវៀតណាមមកជួយទៀតហើយ?

ស្រស់: អស់ហើយ ។

វីរះ : ចុះពួកគេថាខាងអាមេរិកខាងអីមានទ័ពមកជួយទេ?

ស្រស់: មានតែខាងអាមេរិកទេ អាមេរិកគេឲ្យបញ្ជាការជួយខ្វះ ហើយរឿងថាទ័ពអាធិវអីអស់ហើយ គេដកថយអស់ហើយ ។

វីរះ : ហេតុអីអាមេរិកជួយដែរក៏នៅតែចាញ់?

ស្រស់: មិនដឹងយ៉ាងម៉េច?

វីរះ : ប្អូមកពីយើងខ្វាំងដាង?

ស្រស់: យើងខ្វាំងដាង យើងវ៉ៃអត់ខ្វាចស្លាប់ ។

វីរះ : ខាងខ្មែរក្រហមមានចំណុចពិសេសអី ផ្ទាក់លើបំពាក់បំប៉នយ៉ាងម៉េចបានយើងខ្វាំងម្ល៉េះ?

ស្រស់: ខ្វាំងត្រង់រឿងបំពាក់បំប៉នការឈឺចាប់ ថាអ្នកមានជិះជាន់អ្នកក្រ ធ្វើបាបអ្នកក្រ ។ បើតាមគិតមើលទៅខ្វាំងត្រង់ចំណុចហ្នឹងទេ បង្រៀនផ្នែកហ្នឹងទៅឲ្យយើងអ្នកក្រឈឺចាប់ មានកំហឹងចឹងទៅ ។ ត្រង់ចំណុចហ្នឹងមួយខ្វាំងហ្នង ។

វីរះ : ចុះពេលពូចូលទៅដល់ភ្នំពេញដល់ពេលថ្ងៃរំដោះហ្នឹងហ្នងប្អូយ៉ាងម៉េច?

ស្រស់: ចូលទៅដល់វ៉ៃហើយ មុនថ្ងៃរំដោះហ្នឹងវ៉ៃហើយឈ្នះបណ្ដោយ នៅក្នុស្រុកភ្នំពេញ ។

វីរះ : មុនទៅដល់ភ្នំពេញវ៉ៃឈ្នះប៉ុន្មានកន្លែង?

ស្រស់: វ៉ៃទៅចឹងទៅ ដេញទៅរហូត ។ ដេញទៅដល់ភ្នំពេញទ័ពវារលាយឯង ។ ទ័ពលន់ នល់ មិនដឹងទៅណាអស់ ទៅជាស៊ីវិលអស់រលីង អត់មានស្លៀកខោអាវទ័ព ។

វីរះ : ពេលឈ្នះភ្លាមពូធ្វើអីទៀត?

ស្រស់: ពេលឈ្នះភ្លាមសំរាក អត់មានទៅវ៉ៃណាណីទេ ។

វីរះ : ឈ្នះចូលដល់ភ្នំពេញ ។ ចូលដល់ភ្នំពេញឆ្នាំ៧៥ហ្នឹងហ្នង?

ស្រស់: ៧៥ ។

វីរះ : សំរាកយូរទេ?

**ផ្នែកខាង B:**

ស្រលៈ ទៅថ្នាក់លើវាចាត់តាំងយើងទៅតាមកំលាំងទៅតាមអង្គភាព ឲ្យត្រូវធ្វើនេះធ្វើនោះសព្វគ្រប់ទាំងអស់ ខ្លះទៅធ្វើស្រែ ខ្លះនៅការពារហ្នឹងទៅ ខ្លះទៅទ័ពទៅអីគ្រប់មុខក្រសួងទាំងអស់ ។

វីរៈ ៖ ពេលហ្នឹងភ្លាមមានចាប់ផ្ដើមស្គាល់ពូឈ្មោះមេដឹកនាំធំៗ ហើយឬនៅ?

ស្រលៈ នៅបានយូរដែរប្រហែល៣-៤ខែដែរបានចាត់ចែងអ្នកមេដឹកនាំធំៗហ្នឹង ។

វីរៈ ៖ ធំៗមានអ្នកណាខ្លះ?

ស្រលៈ បោះឆ្នោត ។ កាលបោះឆ្នោតហ្នឹងមានតែខៀវ សំផន និងអ្នកធំៗ នួន ជា និងតាឌុច និងតាអៀង សារី ។ ប៉ុនពេលបោះឆ្នោតជាប់ខៀវ សំផន ។

វីរៈ ៖ ភ្លាមៗពេលវៃបាន៣-៤ខែហ្នឹងមានអ្នកណាខ្លះមាន នួន ជា, ខៀវ សំផន, អៀង សារី ។

ស្រលៈ ហ៊ូ នឹម ។

វីរៈ ៖ ហ៊ូ នឹម, ហ៊ូ យន់ ។

ស្រលៈ ហ៊ូ នឹម, ហ៊ូ យន់ ពីរនាក់ហ្នឹង ។

វីរៈ ៖ ពីណាគេទៀតដែលពូភ្លាមៗជំនាន់ហ្នឹង ដែលបោះឆ្នោតអីហ្នឹង?

ស្រលៈ តាឌុច ។ មានតែបុណ្ណឹងនាក់ ។

វីរៈ ៖ ចុះប៉ុល ពត?

ស្រលៈ ប៉ុល ពត អត់ទាន់មានចេញឈ្មោះទេ ។

វីរៈ ៖ អត់ទាន់មានឈ្មោះទេ ។ នួន ជាមួយទៀតម៉េញ ។

ស្រលៈ នួន ជា ពូ ។ អត់មានពូតែប៉ុល ពតទេ ។ ដល់បោះឆ្នោតទៅជាប់ខៀវ សំផន បឹងគាត់ធ្វើប្រធានរដ្ឋទៅ ។

វីរៈ ៖ ចុះអៀង សារី?

ស្រលៈ អៀង សារី កាន់នៅខាងក្រសួងការបរទេស ។

វីរៈ ៖ និយាយពីនួន ជា វិញ ។ នួន ជា គាត់កាន់ខាងអី?

ស្រលៈ នួន ជា មិនដឹងកាន់តំណែងអីទេ គាត់ពូតែឈ្មោះ ។ ដឹងតែពីរនាក់ហ្នឹងទេ ខៀវ សំផន គាត់ធ្វើប្រធានរដ្ឋ ហើយនិងអៀង សារី គាត់ធ្វើក្រសួងការបរទេស ។

វីរៈ ៖ ចុះហ៊ូ នឹម, ហ៊ូ យន់?

ស្រលៈ ហ្នឹងមុខការគាត់មិនដឹងធ្វើអីទៀតទេ គេចាត់ចែងបានធ្វើធំគ្រប់គ្នា ប៉ុនមិនដឹងធ្វើអី ។

វីរៈ ៖ ការបោះឆ្នោតហ្នឹងគេបោះយ៉ាងម៉េច? អ្នកណាគេអ្នកបោះ?

ស្រល់៖ បោះហ្នឹងអ្នកធំៗទាំងអស់គ្នាគេអ្នកបោះ អ្នកដឹកនាំធំៗទាំងប៉ុន្មានហ្នឹងគេចាត់ចែងគ្នាគេចុះឈ្មោះទាំងអស់គ្នា អ្នកណាចុះឈ្មោះបោះឆ្នោតធ្វើប្រធានទៅ ។

វីរៈ ៖ ចុះអៀង ធីរិទ្ធ អីមានពុះហើយប្តូនៅកាលហ្នឹង?

ស្រល់៖ អត់មាន ។

វីរៈ ៖ ប្រពន្ធអៀង សារី?

ស្រល់៖ អត់មានទាន់ពុះទេ ។ ហើយដល់បោះឆ្នោតជាប់ខៀវ សំផន បានប៉ុន្មាន.... ។

វីរៈ ៖ សុន សេន?

ស្រល់៖ សុន សេន ហ្នឹងក៏ពុះដែរ ប៉ុនមិនដឹងគាត់ធ្វើនៅក្រសួងអី ។

វីរៈ ៖ ពុះពេលជំនាន់បោះឆ្នោតដែរ?

ស្រល់៖ ហ្នឹងហើយជំនាន់បោះឆ្នោតហ្នឹងឈ្មោះនៅជាមួយគ្នានៅហ្នឹង ប៉ុនពេលបោះទៅជាប់តែ ខៀវសំផន ។

វីរៈ ៖ ឌុច?

ស្រល់៖ តាឌុចក៏នៅហ្នឹងដែរ ។

វីរៈ ៖ ឌុចគាត់កាន់អីកាន់ប្រធានគុកចឹងទៅពីដំបូងឡើង?

ស្រល់៖ គាត់កាន់តាំងពីមុនបោះឆ្នោត ។

វីរៈ ៖ គាត់កាន់នៅណា? នៅស-២១?

ស្រល់៖ ហ្នឹងហើយ ។

វីរៈ ៖ តាំងពីមុនបោះឆ្នោត?

ស្រល់៖ គាត់កាន់តាំងពីមុនបោះឆ្នោត តាំងពីមិនទាន់មានលេខស-២១ ។

វីរៈ ៖ កាលមុនកន្លែងហ្នឹងគេហៅអី?

ស្រល់៖ គេហៅមិនដឹងទេ ។ ខ្ញុំមិនបានចាំអាកន្លែងហ្នឹងខ្ញុំទៅគេដាក់ឈ្មោះហើយហ្នឹង ដល់ខ្ញុំទៅនៅហ្នឹងដាក់ឈ្មោះស-២១ហ្នង ។

វីរៈ ៖ ឌុចកាន់គុកហ្នឹងពេលដែលដណ្តើមបានភ្នំពេញភ្លាមគាត់កាន់ហ្នង?

ស្រល់៖ បាទ ។

វីរៈ ៖ ហើយភ្លាមៗហ្នឹងចាប់ផ្តើមមានអ្នកទោសហើយប្តូនៅ នៅក្នុងគុកហ្នឹង?

ស្រល់៖ គ្រាន់តែបែកភ្លាមគេរៀបចំ ។

វីរៈ ៖ ចុះពូវិញពេលដែលសំរាកចប់ គេចាត់តាំងពូទៅណាវិញ?

ស្រល់៖ នៅធ្វើស្រែ ។

វីរៈ ៖ ឆ្នាំណា?

ស្រល់៖ ឆ្នាំ៧៥ហ្នឹង ។

វីរៈ ៖ ប្រហែលជាខែប៉ុន្មាន?

ស្រល់៖ ខែ មិនទៀងទៀតត្រឹម៧៥ឈ្នះគេត្រឹមថ្ងៃ១៧មេសា សម្រាកបានប៉ុន្មាន១ខែ ២ខែហ្នឹងមក ។

វីរៈ ៖ ធ្វើស្រែនៅណា?

ស្រល់៖ ធ្វើស្រែនៅស្វាគូ ។

វីរៈ ៖ នៅស្វាគូជិតព្រែកត្នោត?

ស្រល់៖ បាទ!

វីរៈ ៖ ធ្វើហ្នឹងបានរយះពេលយូរទេ?

ស្រល់៖ បានតែ២ខែ ។

វីរៈ ៖ យ៉ាងម៉េចបានតែ២ខែ?

ស្រល់៖ ២ខែដល់នេះទៅអង្គការប្រមូលទ័ពឡើងមកនៅភ្នំពេញវិញ ។

វីរៈ ៖ អ្នកណាគេអ្នកប្រមូលហ្នឹង?

ស្រល់៖ អង្គការហៅមក ។

វីរៈ ៖ គាណាតប្អូយយ៉ាងម៉េច?

ស្រល់៖ មិនទៀងជាគាណាតប្អូអី តែគេថាអង្គការសុទ្ធតែថ្នាក់លើអ្នកធំហើយ ។

វីរៈ ៖ ចុះពូបានដំណឹងពីប្រធានពូហ្នឹងឈ្មោះអីដែរ? ដូចថាអ្នកដែលមកប្រាប់ពូឲ្យទៅហ្នឹង ប្អូយដឹងតាមគ្នាគេហៅឲ្យទៅទ័ពនៅភ្នំពេញវិញ ប្អូក៏មានប្រធានគេប្រាប់ ។

ស្រល់៖ តែនេះប្រធានកងវីរៈគេប្រាប់ហើយ ។

វីរៈ ៖ ប្រធានកងវីរៈហ្នឹងឈ្មោះអី?

ស្រល់៖ ឈ្មោះខន ។

វីរៈ ៖ ខនហ្នឹងអ្នកប្រាប់ ។

ស្រល់៖ ដល់នេះគាត់ប្រាប់តាមកងវរយកងហាឲ្យយើងប្រមូលគ្នាទៅភ្នំពេញវិញហើយ ។

វីរៈ ៖ ម៉េញពូនិយាយថាសម្រាកហើយគេឲ្យមកធ្វើស្រែ ។ ពេលដែលឲ្យមកធ្វើស្រែហ្នឹងអ្នកណាគេអ្នកចាត់តាំងឲ្យមកធ្វើស្រែ?

ស្រលៈ សុទ្ធតែអន្តការថ្នាក់លើទាំងអស់ហ្នឹង ។

វីរៈ ៈ ខនដែរ ។ ចុះហេតុអីបានគេមិនឲ្យយើងទៅធ្វើទ័ពនៅភ្នំពេញ ចាំបាច់ចាត់តាំងឲ្យមកធ្វើ ស្រែសិនធ្វើអី?

ស្រលៈ អាហ្នឹងយើងធ្វើដើម្បីដោះស្រាយជីវភាពសិន ។

វីរៈ ៈ ចឹងពេលហ្នឹងបានន័យថាយើងខ្វះខាត?

ស្រលៈ យើងខ្វះខាតហើយ ។ ទាល់តែធ្វើស្រែដោះស្រាយសិន ព្រោះយើងអត់មានអ្នកណាជួយមកអីណាទេសេដ្ឋកិច្ចចេះតែដាច់ ចឹងហើយសេដ្ឋកិច្ចត្រូវដាច់នោះ ចេះតែធ្វើហូបខ្លួនឯងសិនដល់ហើយបានគេចាត់ចែងតទៀត ។

វីរៈ ៈ នៅស្វាគូហ្នឹងធ្វើស្រែបានរយៈពេល២ខែ?

ស្រលៈ បាទ ២ខែហើយមកភ្នំពេញវិញ ។

វីរៈ ៈ អ្នកធ្វើស្រែហ្នឹងសុទ្ធតែជាយោធា?

ស្រលៈ សុទ្ធតែយោធាទាំងអស់ ។

វីរៈ ៈ ទាំងអស់ប៉ុន្មាននាក់គិតទៅ?

ស្រលៈ វាទូទៅហ្មងទាំងអស់គ្នា ។

វីរៈ ៈ ពេលដែលធ្វើស្រែហ្នឹងមានចាប់ផ្តើមបាត់មនុស្សអីអត់ទេ?

ស្រលៈ អត់មានទេ ។ នៅមូលគ្នាចឹងទៅ ។

វីរៈ ៈ នៅក្នុងក្រុមជាមួយគ្នាហ្នឹង?

ស្រលៈ នៅក្នុងក្រុមហ្នឹងអត់មានបាត់ទៅណាមកណាទេ ព្រោះពេលហ្នឹងគេអត់មានត្រូវកាត់ទោសអូសដំណើរទេ គេបំប៉នយើងណាកាលហ្នឹង ។ ព្រោះយើងទើបតែឆើបចឹងគេបំប៉នយើងហើយគេអត់ហ៊ានធ្វើអីយើងខ្លាំងទេ ។

វីរៈ ៈ ពូដឹងពីមូលហេតុដែលគេរបមូលទ័ពមកភ្នំពេញហ្នឹងក្នុងគោលបំណងអីដែរ?

ស្រលៈ គេប្រមូលដើម្បីគេចាត់ចែងយកកំលាំងទៅវៃទៀត ។

វីរៈ ៈ ចុះក្រែងយើងទទួលបានជ័យជំនះហើយហេតុអីបានវៃទៀត?

ស្រលៈ វៃនៅខាងក្រៅទៀត ។

វីរៈ ៈ ចឹងយើងយកបានភ្នំពេញហ្នឹងមិនទាន់បានឈ្នះទាំងអស់ទេ?

ស្រលៈ យើងឈ្នះអស់រលីងហើយ ប៉ុនយើងប្រមូលហៅទ័ពមកនៅភ្នំពេញដើម្បីចាត់ចែងកំលាំងយកទៅវៃទ័ពទៅស្រុកយួនទៀត ។

វីរះ ៖ វៃជាមួយវៀតណាម?

ស្រល់៖ ហ្នឹងហើយ ។

វីរះ ៖ វៃជាមួយពួកអីគេ?

ស្រល់៖ វៃជាមួយយួនហ្នឹង ។

វីរះ ៖ ហេតុអីបានវៃជាមួយយួន?

ស្រល់៖ វៃជាមួយយួនគេថាយួនយកទឹកដី ។

វីរះ ៖ ទៅវៃនៅទល់ដែន?

ស្រល់៖ ទល់ដែន ។

វណ្ណះ៖ ទៅវៃនៅឆ្នាំណាពូ?

ស្រល់៖ វៃពីចុង៧៥មករហូត ។

វីរះ ៖ ពូបានទៅវៃអត់ទេ?

ស្រល់៖ ខ្ញុំអត់បានទៅទេ ខ្ញុំនៅជាប់ត្រឹមហ្នឹងខ្ញុំនៅធ្វើការអីក្នុងនេះវិញ ខ្ញុំអត់មានទៅវៃទេ ។ ខ្ញុំត្រូវគេចាត់តាំងឲ្យមកធ្វើការនៅក្នុងភ្នំពេញវិញ ។

វីរះ ៖ ពូអត់បានទៅ ពូនៅធ្វើការនៅភ្នំពេញនៅកន្លែងណា?

ស្រល់៖ កាលហ្នឹងគេជ្រើសរើសទៅមន្ទីរ២១ ។

វីរះ ៖ មួយក្រុមពូមានគ្នាប៉ុន្មាននាក់បានទៅមន្ទីរស-២១ហ្នឹង?

ស្រល់៖ កាលហ្នឹងខ្ញុំចេញពីកន្លែងទៅគេរើសទៅមួយក្រុមមួយនាក់ពីរនាក់ចឹងទៅចុំរុះគ្នា ដល់ពេលចេញចូលទៅក្នុងមន្ទីរស-២១ហ្នឹងមានគ្នា២០០នាក់ ។

វណ្ណះ៖ កងការពារទាំងអស់២០០នាក់?

ស្រល់៖ អត់ទេកាលហ្នឹងខ្ញុំចេញទៅ គេរើសយកទៅ ។ មកពីអង្គភាពគេខ្លះទៅ ដល់ទាំងអស់គ្នាជុំគ្នាចេញទៅ អាហ្នឹងចំនួនយុទ្ធជនទ័ព២០០នាក់ ។

វីរះ ៖ ២០០នាក់ហ្នឹងនៅក្នុងគុកហ្នឹងហ្នឹងឬយ៉ាងម៉េច?

ស្រល់៖ អត់ទាន់ទៅទេ ។

វីរះ ៖ ហ្នឹងគេគ្រាន់តែប្រមូល ។

ស្រល់៖ គេប្រមូលបាន២០០នាក់ហើយបានគេហៅទៅការពារនៅហ្នឹងហ្នឹង ។

វណ្ណះ៖ ចឹងទៅដល់កន្លែងការពារហ្នឹងប៉ុន្មាននាក់ទាំងពូ? ក្នុងមួយក្រុមពូ?

ស្រល់៖ ដល់ចូលទៅគេចែកជាក្រុមៗហើយ ។ មួយក្រុម១០នាក់ ។

វណ្ណៈ ចុះក្រុមពូ ពូស្គាល់ឈ្មោះពីណាខ្លះ?

ស្រល់ៈ ភ្លេចអស់ហើយ ។

វណ្ណៈ អាចចាំបានខ្លះទេអ្នកដែលជិតស្និតជាមួយពូហ្នឹង?

ស្រល់ៈ ភ្លេចអស់ហើយខ្ញុំក្មេងៗតូចៗ ហើយនៅឆ្ងាយពេក នៅអមលាំង ។

វណ្ណៈ ចឹងពូចូលទៅដល់មន្ទីរស-២១នៅក្នុងឆ្នាំណា?

ស្រល់ៈ ចុង៧៥ ។

វណ្ណៈ ចុង៧៥ហ្នឹងរហូតហ្នឹង ទល់តែបែកហ្នឹង?

ស្រល់ៈ ទល់តែបែកហ្នឹង ។

វីរៈ ៈ ម៉េញពូមានប្រសាសន៍ថា២០០នាក់ហ្នឹងមិនមែនទ័ពចេញទៅទល់ដែនខ្លះ ចូលស-២១ខ្លះ?

ស្រល់ៈ អាហ្នឹងជ្រើសរើសតាមអង្គភាពមក២០០នាក់ ។

វីរៈ ៈ ហើយចាត់ចែងចូលទៅក្នុងស-២១ទៅ?

ស្រល់ៈ ហើយគេនាំចូលទៅការពារនៅកន្លែងស-២១ ។

វីរៈ ៈ អ្នកណាគេអ្នករើសកាលហ្នឹង?

ស្រល់ៈ ហ្នឹងគេនិយាយតែថាថ្នាក់លើ សុទ្ធតែអង្គការ ។

វីរៈ ៈ ចឹងចូលខនហ្នឹងទៀតហើយ?

ស្រល់ៈ អត់ទេ មិនមែនខនទេ អង្គការថ្នាក់លើឡើរើសទៅ ។ គេនិយាយថាអង្គការៗហ្នឹងហ្នឹង ។

វីរៈ ៈ ពេលពូទៅដល់ស-២១ភ្លាម គេឲ្យពូធ្វើអីគេ?

ស្រល់ៈ ទៅដល់គេឲ្យការពារ ឲ្យយាម ។

វីរៈ ៈ យាមអ្នកណា?

ស្រល់ៈ យាមអ្នកទោស ។

វីរៈ ៈ យាមអ្នកទោស ។ រយៈពេលយូរទេ ពូធ្វើនៅស-២១?

ស្រល់ៈ តាំងពី៧៥រហូតដល់បែក ។

វីរៈ ៈ រហូតដល់បែក ។ ចឹងប្រហែលជាពូស្គាល់អ្នកទោស អ្នកយាមគុកអី ដូចហ៊ិ, ឌុច អីពូសុទ្ធតែបានឃើញផ្ទាល់ៗហើយ ។

ស្រល់ៈ ហ្នឹងនៅជាមួយគ្នា ។

វីរៈ ៈ អ្នកយាមគុកនៅទួលស្លែងតាំងពីពូនៅចឹងមានប៉ុន្មាននាក់?

ស្រល់៖ អ្នកយាមវាច្រើន វាចែកផ្នែកគ្នា ដូចថាគ្នាអ្នកយាមចឹងគ្នាគេ២០០ ហើយគេអ្នកសួរចំលើយចឹងគ្នាគេ១០០ដោយៗខ្លួនចែកតាមផ្នែកគ្នា ។

វីរះ ៖ មានអ្នកសួរចំលើយផ្សេង មានអ្នកយាមផ្សេង?

ស្រល់៖ ផ្សេង មិនអាចច្របូកច្របល់គ្នាបានទេ ។

វីរះ ៖ ចឹងអាចមានដល់២០០នាក់អ្នកយាមគុកហ្នឹង?

ស្រល់៖ ២០០ ព្រោះដូរ ។

វីរះ ៖ ដូរយ៉ាងម៉េច?

ស្រល់៖ ដូរវេនគ្នា ។

វីរះ ៖ ដូរវេនគ្នា?

ស្រល់៖ ហ្នឹងហើយ ។

វីរះ ៖ ចុះពួគេដូរដូចថាពេលព្រឹកអ្នកនេះយាម ពេលយប់អ្នកនោះយាម ឬមួយក៏យ៉ាងម៉េច?

ស្រល់៖ ហ្នឹងហើយគេដូរវេនគ្នាចឹង ។ ដូចថាយើងចូលម៉ោង៦ចឹង ដល់ម៉ោង១២ដល់ម៉ោងបាយ យើងគេមកដូរយើងទៅហូបបាយ ដល់ថ្ងៃរសៀលហ្នឹងយើងសំរាកធ្វើការងារយើងតាម ក្រុមហ្នឹង ដល់ម៉ោង៦ល្ងាចយើងហូបបាយហើយចូលដូរគេវិញ ។

វីរះ ៖ ចង់និយាយថាមួយស-២១ហ្នឹង ពួយាមមួយពេលមានគ្នាប៉ុន្មាននាក់? តែមួយពេលឥឡូវថាពូ និងអ្នកផ្សេងៗយាមពេលថ្ងៃជាមួយពូមានគ្នាប្រហែលប៉ុន្មាននាក់?

ស្រល់៖ មួយពេល១០០ ។

វីរះ ៖ ១០០ ។ ចឹងច្រើនហើយ?

ស្រល់៖ ច្រើន ។ មានក្នុង មានគៀនតាមគេម ហើយមានក្រៅទៀត ។

វណ្ណះ៖ មានប៉ុន្មានជាន់ពូ?

ស្រល់៖ បើគិតជាយាមវិញតាមខ្សែរសំខាន់ខាងក្នុងមានពីរជាន់អាហ្នឹងកន្លែងសំខាន់ ។ ហើយខាងខ្សែរទីបីខាងក្រៅហ្នឹងយាមតាមច្រកៗទេ ។

វីរះ ៖ ពូយាមផ្ទាល់ជាមួយអ្នកទោស?

ស្រល់៖ ជួនកាលក៏នៅផ្ទាល់ ជួនកាលក៏នៅខាងក្រៅ ។

វីរះ ៖ ទិដ្ឋភាពនៅក្នុងគុកហ្នឹងអ្នកទោសចេញចូលៗរហូតឬមួយក៏យ៉ាងម៉េច? ដូចថាមានគេដឹកចូលរហូតឬមួយយ៉ាងម៉េច?

ស្រល់៖ គេដឹកចេញចូលហែហូររហូតជាប់ ។

វីរៈ ៖ ចេញចូលរាល់ថ្ងៃហ្នុង?

ស្រល់ៈ រាល់ថ្ងៃ ។

វីរៈ ៖ ពេលដែលដឹកមកគេដាក់អីមក?

ស្រល់ៈ ដាក់ឡាន ។

វីរៈ ៖ ដាក់ឡានមក ។ ហើយមួយឡានៗមានប្រហែលប៉ុន្មាននាក់?

ស្រល់ៈ ជួនកាលបើយើងចាប់តាមអ្នកធ្វើការដូចថាតាមស្រុក តាមខេត្តរាយៗអី ហ្នឹងយើងមកចាប់ដល់ៗកន្លែង ។ ហើយបើចាប់ទ័ពដឹកទៅទាំងអស់ហ្នុង ។ ដឹកទាំងឡានៗចូលទៅដល់ក្នុងហ្នុង ។

វីរៈ ៖ ចូលទៅដល់ក្លាមយ៉ាងម៉េច គេដាក់ចូលបន្ទប់ហ្នងឬមួយយ៉ាងម៉េច?

ស្រល់ៈ ចូលទៅដល់ក្លាមគេនាំចូលទៅក្នុងអគារហ្នុង ។

វីរៈ ៖ វៃខ្នោះដែរអ្នកមកហ្នឹង?

ស្រល់ៈ អត់ ។

វីរៈ ៖ អត់មានទេ ។

ស្រល់ៈ អត់វៃអត់អី មកទទេរ ។ គ្នារាប់រយនាក់ចឹងវៃឆាប់ម៉េចកើត ចឹងហើយដឹកយកចូលទៅ ទៅវៃខ្នោះលើហ្នឹងហ្នុង ។

វីរៈ ៖ ចុះប្រសិនបើមួយថ្ងៃចូលរាប់រយចឹង ចុះវាមិនចាល់ហើយ? ឬក៏គេបញ្ចេញតាមហ្នឹង?

ស្រល់ៈ ចេញក៏ចេញ ។

វីរៈ ៖ ចេញដែរ ។

ស្រល់ៈ ចេញជួនកាលមួយខែចឹងបញ្ចេញពីរដង ។

វីរៈ ៖ សួរថាអ្នកចេញហ្នឹងសុទ្ធតែចេញទៅ....?

ស្រល់ៈ អ្នកអស់ចម្លើយហើយ ។

វីរៈ ៖ អស់ចម្លើយយ៉ាងម៉េច?

ស្រល់ៈ គេសួរចម្លើយអស់រលីង ។

វីរៈ ៖ សួរអស់តែគេបញ្ចេញហ្នឹងគេយកទៅសំលាប់ឬមួយយ៉ាងម៉េច?

ស្រល់ៈ គេយកទៅសំលាប់ចោល ។ ដាក់ឡានយកទៅសំលាប់ចោលទៀត ។

វីរៈ ៖ ហើយទាំងឡានចូលទាំងឡានចេញហ្នឹងគេមានបិទអីមិនឲ្យឃើញដែរទេ?

ស្រល់ៈ អត់ឃើញទេ ។

វីរៈ ៖ បិទជិតឈឹងហ្នុង?

ស្រល់ៈ ជិតឈឺង ចូលក៏បិទទ្វារហ្នឹងដឹកពីណាមកក៏បិទ ដល់ចេញទៅវិញក៏បិទអត់ឲ្យមានឃើញទេ ។

វីរះ ៈ ម៉េញពូមានប្រសាសន៍ថាគេយកទៅវៃចោល ហើយហេតុអីបានពូដឹងថាអីចឹង?

ស្រល់ៈ បានជាដឹងព្រោះយើងនៅក្នុងហ្នឹងយើងតែនេះទៅគេនិយាយហើយ ។

វីរះ ៈ អ៎ អ្នកធ្វើការ?

ស្រល់ៈ អ្នកធ្វើការជាមួយគ្នាគេចេះតែនិយាយហើយ ត្រង់យើងអ្នកការពារយើងអត់ដឹងទេ អត់មានដឹងថាគេចេញប៉ុន្មាន យកទៅប៉ុន្មានទេយើងអត់ដឹងទេ ទាល់តែគេអ្នកទៅធ្វើការគេមកវិញគេនិយាយ ។

វីរះ ៈ អ្នកដែលដឹកយកទៅ?

ស្រល់ៈ ហ្នឹងហើយ អ្នកដែលដឹកទៅហ្នឹងមកវិញគេនិយាយបានយើងដឹង ។

វីរះ ៈ ចុះពូមានចាំឈ្មោះម្នាក់ពីរនាក់ទេ?

ស្រល់ៈ អត់មានចាំទេ ។ ពួកដែលដឹកទៅហ្នឹងគេខាងផ្សេងដោយខ្លួនទៀត ។

វីរះ ៈ ចុះការនិយាយស្តីនៅកន្លែងធ្វើការហ្នឹងគេឲ្យផ្នែកផ្សេងៗអាចនិយាយទាក់ទងជាមួយគ្នាបានទេ?

ស្រល់ៈ បាន និយាយបានតាមចិត្ត ។

វីរះ ៈ ពូម៉េញមានប្រសាសន៍ថាមួយខែគេដឹកចេញពីរដង ឬក៏បីដង?

ស្រល់ៈ វាអត់ទៀងទេ ជួនកាលកាលណាចូលមកច្រើន ក៏ដឹកចេញញឹកទៅ ។

វីរះ ៈ ញឹកទៅ ។ ចេញទៅម្តងៗដឹកចេញប្រហែលប៉ុន្មានឡាន?

ស្រល់ៈ ទៅជួនកាល១០០នាក់ចឹងទៅ ជួនកាល២០០នាក់ទៅ ។

វីរះ ៈ ហ្នឹងសុទ្ធតែគេសួររកចម្លើយអស់ហើយ?

ស្រល់ៈ សួរចម្លើយអស់រលីង ។

វីរះ ៈ ចុះមានអ្នកដែលគេសួរហើយបញ្ជូនទៅរួចខ្លួនអីដែរអត់ទេ?

ស្រល់ៈ អត់មានទេ ។

វីរះ ៈ អ្នកដែលចូលក្នុងហ្នឹងគឺសួរហើយត្រូវយកទៅវៃចោលហ្នុង...?

ស្រល់ៈ គឺត្រូវងាប់ហ្នុង ។ មិនថាអ្នកការពារហ្នឹង ឬដឹកចូលពីណាទេ ឲ្យតែដឹកចូលហ្នឹងគឺងាប់ហ្នុង ។ សូម្បីតែខ្ញុំការពារហ្នឹងក៏ដោយឲ្យតែជាប់គុកហ្នឹងគឺងាប់ហើយអត់មានអនុគ្រោះបានទេ ។

វីរះ ៈ ទាក់ទងនឹងសួរចំលើយ ការសួរចម្លើយរបស់គេវាយ៉ាងម៉េចដែរកាលហ្នឹង?

ស្រល់៖ រាកន្លែងសួរចម្លើយយើងមិនអាចដឹងបានទេកន្លែងហ្នឹង ព្រោះយើងនៅខាងការពារនោះគិតតែការពារ គេសួរចម្លើយគេគ្រាន់តែមកយកមនុស្សហើយទៅបាត់ មានកន្លែងគេនៅនោះ ។

វីរះ ៖ ពូមានចាំ មានស្គាល់អ្នកសួរចម្លើយខ្លះទេតាមរយះអ្នកនៅជាមួយពូអី?

ស្រល់៖ ស្គាល់ឈ្មោះដែរ ប៉ុន្តែយូរៗទៅវាយូរពេកទៅភ្លេចអស់ហើយ ។

វីរះ ៖ ពូរសាកព្យាយាមនឹកមើល?

ស្រល់៖ ភ្លេចអស់ហើយ សូម្បីតែអ្នកការពារនៅជាមួយគ្នាហ្នឹងក៏ភ្លេចអស់ហើយ ។

វីរះ ៖ អត់ចាំ ។

ស្រល់៖ អត់ចាំ ។

វីរះ ៖ មានអ្នកនៅរស់ដល់សព្វថ្ងៃនេះទេ?

ស្រល់៖ មាន ។

វីរះ ៖ ឈ្មោះអីខ្លះអ្នកដែលនៅរស់?

ស្រល់៖ នៅរស់ឃើញមាននៅក្រោមមួយ ប៉ុន្តែគ្នាមិនដឹងស្លាប់ហើយឬនៅទេ ឈឺយូរហើយ ។

វីរះ ៖ ឈ្មោះអីទៅ?

ស្រល់៖ ឈ្មោះគាន់ នៅក្រោម ។

វីរះ ៖ ភូមិគេហៅភូមិលេខប៉ុន្មាន?

ស្រល់៖ មិនដឹងលេខប៉ុន្មានទេ ទៅចុងខ្សាច់ ។

វីរះ ៖ នៅជិតយើងនេះដែរ?

ស្រល់៖ នៅទល់ដែន ។

វីរះ ៖ ពេលដែលពូនៅយាមនៅគុកជ្រាល់ចឹង ពូឃើញសកម្មភាពអ្នកទោសទាំងអស់ហ្នឹងយ៉ាងម៉េចដែរ ដូចថាត្រូវរបង ត្រូវគេធ្វើទារុណកម្ម ស្នាមរបួសស្នាមអីមានទេ?

ស្រល់៖ មាន ។

វីរះ ៖ ឃើញផ្ទាល់ជាក់ស្តែង?

ស្រល់៖ ជាក់ស្តែងហ្នឹងឃើញ ។ យើងមិនបានឃើញគេធ្វើទារុណកម្មនៅកន្លែងសួរចម្លើយ ប៉ុន្តែយើងគ្រាន់តែឃើញដូចថាគេយកមកទុកឲ្យយើងវិញហើយយើងឃើញហ្នឹង ។

វីរះ ៖ ចឹងអ្នកទោសដែលបានដេកនៅហ្នឹងសុទ្ធតែត្រូវគេធ្វើបាបវៃទាំងអស់ហ្នឹងហ្មង?

ស្រល់៖ វៃទាំងអស់ ។

វីរះ ៖ ឃើញស្នាមរបួសជាប់នៅហ្នឹងហ្មង?

ស្រល់៖ ស្នាមដាំ បែកសាច់បែកខ្ទង ដំបៅ ។

វីរះ ៖ ពូដែលដាក់បាយឲ្យអ្នកអស់ហ្នឹងទេ?

ស្រល់៖ បាយឲ្យស៊ីរាល់ថ្ងៃ ។

វីរះ ៖ ពូដែលដាក់បាយឲ្យអ្នកអស់ហ្នឹងទេ?

ស្រល់៖ បាយឲ្យស៊ីរាល់ថ្ងៃ ។ យើងអ្នកយាមហ្នឹងហើយ យើងអ្នកដាក់ឲ្យ ។ គេគ្រាន់តែយកបាយឲ្យយើង យើងដើរចែកឲ្យទៅ ។

វីរះ ៖ ខ្ញុំសួរបកទៅក្រោយវិញថាការដែលពូបានក្លាយមកជាអ្នកយាមហ្នឹងថាដោយសារមូលហេតុអីបានពូអាចបានមកនៅស-២១ហ្នឹង ពូមានប្រវត្តិរូបអីមិនពាក់ព័ន្ធខ្លាំង ឬមួយយ៉ាងម៉េច?

ស្រល់៖ គេយកទៅកន្លែងហ្នឹងគេសំរាំងប្រវត្តិរូបរបស់យើងកាលណាមានពាក់ព័ន្ធមានអីគេអត់យកទេ គេយកប្រវត្តិរូបដែលស្អាតហ្នង អត់មានពាក់ព័ន្ធមានអីទេ ។

វីរះ ៖ ប្រវត្តិរូបពូតាំងពីដើមមកអត់មានពាក់ព័ន្ធអីទេ?

ស្រល់៖ អត់ ។

វីរះ ៖ ចុះពីជំនាន់លន់ នល់ មុនៗ ជំនាន់សម្តេចអី គ្រួសារពូជាអ្នកយ៉ាងម៉េចដែរ?

ស្រល់៖ ជាអ្នកស្រែចំការ ធ្វើស្រែធ្វើចំការ ។

វីរះ ៖ អត់មានបងប្អូនធ្វើការធ្វើគ្រូបង្រៀន ធ្វើប៉ូលីសអីទេ?

ស្រល់៖ អត់មានសុទ្ធ ។ គេយកតែអ្នកស្រែចំការ និងថ្នាក់កណ្តាល ។

វីរះ ៖ ចុះពូមានឃើញអ្នកណាគេម្នាក់ត្រូវគេធ្វើបាបរហូតដល់ស្លាប់ក្នុងគុកហ្នឹងដែរអត់ទេ?

ស្រល់៖ មាន ។

វីរះ ៖ មានដែរ? ពូឃើញដែរ?

ស្រល់៖ មាន ។

វីរះ ៖ មានចាំខ្លះទេថាអ្នកហ្នឹងចូលមកពីខាងណា គាត់តួនាទីអីខ្លះបានគេធ្វើបាបគាត់ដល់ថ្នាក់ស្លាប់?

ស្រល់៖ ជួនណាច្រើនខាងកងវីរៈ ។

វីរះ ៖ កងវីរៈ ។

ស្រល់៖ ជួនណាវីរសេនាធំ ជួនណាវីរសេនាតូចចឹងទៅ ដូចចម្លើយគេយកទៅសួរយើងអត់ឆ្លើយ ។

វីរះ ៖ នៅក្នុងកងវីរៈហ្នឹងមេកងវីរៈ?

ស្រល់៖ មេចឹងទៅ បើយើងក្បត់គេចាប់យកមកដាក់គុកហ្នឹង ។

វីរះ ៖ ពូឃើញប៉ុន្មាននាក់ដែរដែលត្រូវគេសំលាប់ វ៉ៃរហូតដល់ស្លាប់?

ស្រល់ៈ វាហែហូជាប់រហូតមកហ្នឹង រឿងកំណត់អត់មានកំណត់ទេ ។

វីរៈ ៖ រាប់ក្មេច ។

ស្រល់ៈ អត់មានរឿងកំណត់ថាប៉ុន្មាននាក់ៗអីទេ វាហែរហូរ ។ ជួនកាលខាងអគារគេនោះទៅ ជួនកាលខាងអគារយើងនេះទៅ ។

វីរៈ ៖ ពូឃើញផ្ទាល់ទេកាលដែលគេវ៉ៃហើយឲ្យមានមនុស្សស្លាប់ចឹង? ពូមានដែលឃើញផ្ទាល់នឹងភ្នែកទេ?

ស្រល់ៈ គេយកទៅសំលាប់អត់ដែលឃើញ ។

វីរៈ ៖ ពេលនៅក្នុងគុកហ្នឹងដូចថាវ៉ៃដល់ស្លាប់ហ្នឹង?

ស្រល់ៈ វ៉ៃទល់ស្លាប់ ឈឺវ៉ៃវាយកទៅសួរចម្លើយកន្លែងហ្នឹងមកហើយបានបញ្ជូនមកកន្លែងយើងដល់ទារុណកម្មខ្លាំងទៅ ។ ដល់ទារុណកម្មខ្លាំងហ្នឹងយើងអ្នកការពារមើលទៅថាមិនអាចធានាបានទេអ្នកជំងឺហ្នឹង យើងរាយការណ៍ឲ្យគេអ្នកដើរចល័តរាយការណ៍ទៅពេទ្យឲ្យពេទ្យមកមើលដើម្បីការពារខ្លួនយើងខ្លាចអ្នកទោសហ្នឹងស្លាប់យើងជាប់គុកជំនួសអ្នកទោស ហ្នឹងគេគិតចឹង ។

វីរៈ ៖ ពូមានចាំអ្នកណាគេម្នាក់ទេ ខាងផ្នែកសួរចំលើយ? មានស្គាល់ម្នាក់ទេ?

ស្រល់ៈ អ្នកសួរចម្លើយហ្នឹងចាំខ្លះ ងាប់អស់ទៅហើយមិនដឹងនៅអីណា ។

វីរៈ ៖ ឈ្មោះអីខ្លះ?

ស្រល់ៈ ឈ្មោះនោះច្រើនមិនដឹងឈ្មោះអីខ្លះទេ ហើយវាក្មេង ណាមួយច្រើនស្លាប់អស់ទៅទៀត ។

វីរៈ ៖ អត់មានអ្នកនៅរស់ទេ?

ស្រល់ៈ អត់ ។ ហើយដល់អ្នកកាន់កាប់អ្នកចម្លើយហ្នឹងមិនមែនតាឌុចទេអ្នកកាន់កាប់ចម្លើយ ។ សួរចម្លើយគាត់ឲ្យកូនចៅគាត់សួរ ។

វីរៈ ៖ ចឹងមានន័យថាឌុចជាអ្នកបញ្ជាផ្ទាល់?

ស្រល់ៈ គាត់អ្នកបញ្ជាផ្ទាល់ ។

វីរៈ ៖ ចុះមានពេលខ្លះគាត់សួរផ្ទាល់ខ្លួនគាត់ទេ?

ស្រល់ៈ កាលណានេះគាត់សួរខ្លួនគាត់ដែរហ្នឹង ។ កាលណាចាប់អ្នកដឹកនាំធំៗអាហ្នឹងសួរខ្លួនគាត់ ។

វីរៈ ៖ ពូដឹងតាមរយៈអ្នកណាគេថាគាត់មកសួរផ្ទាល់?

ស្រល់ៈ គាត់ ឃើញគាត់ចឹងហ្មង គាត់មកដល់កន្លែងហ្នឹងហើយយកទៅសួរ ជួនកាលគាត់អត់យកទៅណាឆ្ងាយទេ គាត់សួរនៅមុខហ្នឹងហ្មង ។

វីរះ៖ ពាក្យសំដីដែលគាត់និយាយមកពូគិតថាការសួរចម្លើយរបស់គាត់របៀបថាចង់សំលាប់អ្នក ហ្នឹងចង់បានចម្លើយពីអ្នកហ្នឹងទេ ដូចថាទោះបីធ្វើទារុណកម្មម៉េចក៏ដោយក៏គាត់ធ្វើដែរ តើវាចឹងដែរអត់ទេ?

ស្រល់៖ ដល់គាត់អ្នកដឹកនាំចឹងគាត់សួរចម្លើយគាត់សួរអត់មាននិយាយខ្លាំងៗ គាត់និយាយស្រួលស្អាតហ្នឹង និយាយស្អាតស្រួលបួលដូចយើងនិយាយធម្មតា ។

វីរះ ៖ មានដែលឃើញគាត់វ៉ៃដំអីទេ?

ស្រល់៖ អត់មានទេ ។

វីរះ ៖ ប៉ុនគាត់ប្រើកូនចៅគាត់?

ស្រល់៖ កូនចៅគាត់ហ្នឹងសួរតែខ្លួនគេទៅ គេថាខាងកូនចៅគាត់សួរយ៉ាងម៉េច ល្បិចម៉េចឲ្យតែបានចម្លើយចេញឲ្យគាត់ ហើយមេធំៗទុកឲ្យគាត់សួរ សួរផ្នែកនយោបាយ អត់មានធ្វើបានធ្វើអីទេ ។

វីរះ ៖ ពូគិតថាកាលដែរសួរចម្លើយ និងការវ៉ៃដំ ធ្វើទុកបុកម្នេញយកចម្លើយសារភាពហ្នឹងគឺសុទ្ធសឹងតែបញ្ជារបស់ឌុចឲ្យធ្វើចឹង ឬមួយក៏អ្នកដែលធ្វើហ្នឹងគេធ្វើខ្លួនឯង?

ស្រល់៖ ហ្នឹងចេញបញ្ជាពីឌុចហ្នឹង ។

វីរះ ៖ អាចករណីខ្លះមិនមានពីតាឌុចមកដែរអត់ទេ?

ស្រល់៖ អត់ទេ ទាល់តែបញ្ជាមក បើយើងហ៊ានខុសបញ្ជាត្រូវយើងមានទោស ។

វីរះ ៖ ចុះអ្នកណាគេដែលបញ្ជាតាឌុចបន្តទៀត?

ស្រល់៖ បញ្ជាតាឌុចតមកទៀតដូចអត់មាន ។

វីរះ ៖ នួន ជា?

ស្រល់៖ នួន ជា ក្រសួងគាត់ដោយខ្លួន ។

វីរះ ៖ ដែលចុះមកទេនួន ជា?

ស្រល់៖ អត់ដែលមកហ្នឹងទេ ព្រោះមានតែតាឌុចមួយទេដែលបញ្ជាលើអ្នកទោស ។

វីរះ ៖ តែខ្ញុំចង់និយាយថាឌុចហ្នឹងមានសិទ្ធអំណាចនៅមន្ទីរហ្នឹងហើយ តែវាអាចមានបញ្ជាពីថ្នាក់លើមកឲ្យធ្វើចឹង ឬក៏ឌុចហ្នឹងជាអ្នកសម្រេចចិត្តធ្វើដោយខ្លួនឯង?

ស្រល់៖ អាហ្នឹងថាគាត់សម្រេចខ្លួនគាត់ក៏បាន ព្រោះគាត់ឡើងទៅប្រជុំ ។

វីរះ ៖ បាទ! ការប្រជុំហ្នឹងប្រហែលជាមាននិយាយពីផែនការធ្វើទារុណកម្ម ដើម្បីយកចម្លើយហ្នឹងប្រហែលជាមាន ។ អាចមានអីដែរអត់ទេ?

ស្រលៈ មាន ។ គាត់ទៅប្រជុំថ្នាក់ធំៗចឹងមក ហើយដល់គាត់មកធ្វើការសម្រេចចេញលើគាត់ទាំង អស់ គាំងពីឯកសារអីក៏ដោយ ។

វីរះ ៈ ពូដឹងថាគាត់ទៅប្រជុំហ្នឹងទៅជួបអ្នកណាគេខ្លះ?

ស្រលៈ ជួបតែគ្នាគាត់អ្នកធំៗប៉ុន្មាននាក់ ។

វីរះ ៈ ឥឡូវតាំងពីពូចូលទៅមន្ទីរស-២១ហ្នឹង ពូដែលឃើញខៀវ សំផន, ប៉ុល ពត, អៀង សារី, នួន ជា ចុះមកមើលទស្សនៈកិច្ចអីដែរអត់ទេ?

ស្រលៈ ឃើញមកតែប៉ុល ពតទេ ។

វីរះ ៈ ប៉ុល ពត ធ្លាប់មកដែរ?

ស្រលៈ មក ។

វីរះ ៈ មកញឹកញាប់ទេ?

ស្រលៈ មក...ជួនកាលមួយឆ្នាំមកពីរដង ហើយមកហ្នឹងជួនកាលសឹងតែមិនស្គាល់ទៀតនោះ ។ យើងគ្រប់គ្នាសឹងតែមិនស្គាល់ព្រោះគាត់មកតែម្នាក់ៗឯង បើកឡានមក ។

វីរះ ៈ រូបរាងគាត់យ៉ាងម៉េចដែរ?

ស្រលៈ ហ៊ឺ ហ៊ឺ......

វីរះ ៈ អត់ទេ ចង់និយាយថាគាត់មើលទៅកាត់ចិន មុខខ្មែរ ស ខ្មៅអី ។

ស្រលៈ តាមមើលគាត់កាត់ចិន មិនចិនកាត់ខ្មែរទេទៅជាយួនកាត់ចិនវិញ ។

វីរះ ៈ ពេលដែលមកហ្នឹងពូឃើញផ្ទាល់?

ស្រលៈ មកហ្នឹងគាត់ដើរមក...

វីរះ ៈ អ្នកទោស?

ស្រលៈ អត់ចូលទេ គាត់នៅតែមន្ទីរខាងក្រៅទេ ។

វីរះ ៈ គាត់មកហ្នឹងមកជួបជាមួយឌុច ឬក៏មក...?

ស្រលៈ មកជួបតែជាមួយតាឌុចទេ ។

វីរះ ៈ ការជួបគ្នាហ្នឹងមានរយៈពេលយូរទេ?

ស្រលៈ តែមួយម៉ោងៗអស់ហើយ ។

វីរះ ៈ តែមួយម៉ោង ។ មួយឆ្នាំមកប្រហែលពីរបីដងអីដែរ?

ស្រលៈ មកពីរដង ។

វីរះ ៈ គាត់មិនដែលចូលផ្ទាល់ជួបអ្នកទោសទេ?

ស្រល់៖ អត់ ។ មកដល់ចូលកន្លែងមន្ទីរ ជួនកាលមកតែផ្ទះតាឌុច ។

វីរះ ៖ ចង់សួរថានៅមន្ទីរស-២១ហ្នឹងហ្នង់តើមានអ្នកណាខ្លះដែលធំៗដឹកនាំនៅក្នុងមន្ទីរហ្នឹង មានឈ្មោះអីខ្លះ?

ស្រល់៖ មានតែពីរនាក់ទេ ។

វីរះ ៖ ឈ្មោះអីខ្លះ?

ស្រល់៖ មាតាឌុចមួយ និង តាហ៊ិ ។

វីរះ ៖ តាហ៊ិត្រូវជាយ៉ាងម៉េចតួនាទីគាត់នៅហ្នឹង?

ស្រល់៖ គាត់ហ្នឹងអនុ ។

វីរះ ៖ អនុប្រធានគុកហ្នឹងហ្នង ។ ឌុចមកហ៊ិហ្នង?

ស្រល់៖ ហ្នឹងហើយ ។

វីរះ ៖ ហើយហ៊ិហ្នឹងយ៉ាងម៉េចដែរ?

ស្រល់៖ ហ៊ិហ្នឹងខាងការពារ

វីរះ ៖ ការពារមើលអ្នកទោស?

ស្រល់៖ គាត់អ្នកមើលអ្នកទោស ហើយតាឌុចគាត់អ្នកចម្លើយ ។

វីរះ ៖ ហើយគិតថាហ៊ិហ្នឹងដូចឌុចដែរអត់ទេ មនុស្សតែមួយឬមួយយ៉ាងម៉េច? ចង់និយាយពីការបញ្ជាអីស្រដៀងគ្នាដែរអត់?

ស្រល់៖ ដូចគ្នា ។

វីរះ ៖ ដូចគ្នាដែរ ។ ហ្នឹងឌុចបញ្ជាមកហ៊ិ, ហ៊ិបញ្ជាមកក្រោមតទៀតឬយ៉ាងម៉េច?

ស្រល់៖ ហ្នឹងគាត់ជុំគ្នាចឹងទៅ ឌុចគាត់ខាងចម្លើយគាត់ស្រាវជ្រាវខាងចម្លើយចឹង គាត់ស្រាវជ្រាវខាងចម្លើយ ។ ហ៊ិ គាត់ខាងការពារ គាត់បញ្ជាការឲ្យកូនចៅគាត់ការពារអ្នកទោស អ្នកទោសណាធ្វើ សកម្មភាពអីម៉េចៗលើគាត់ទាំងអស់គាត់តាមដានហ្នឹង ។

វីរះ ៖ ចុះឥឡូវមានអ្នកទោសធ្វើសកម្មភាពផ្សេងនៅក្នុងគុកហ្នឹងច្រើនទេ? ពូមានចាំសកម្មភាពខ្លះ ទេធ្វើសកម្មភាពអីខ្លះទៅអ្នកដែលមានសកម្មភាព?

ស្រល់៖ ច្រើនតែចង់ក និងកាត់សសៃដៃខ្លួនឯង មានតែសកម្មភាពប៉ុណ្ណឹង ។

វីរះ ៖ ចុះឥឡូវឧបមាថាមានអ្នកទោសចងក កាត់សសៃដៃចឹង សួរថាហ៊ិហ្នឹងមានវិធានការអីចំពោះអ្នកយាមអីដែរអត់?

ស្រល់៖ ដកចេញ ។ បើស្លាប់ចាប់អ្នកយាមដាក់គុក

វីរះ ៖ ម៉េចបានពូដឹងថាចឹង?

ស្រល់៖ អាហ្នឹងបើឃើញចឹង ។

វីរះ ៖ មានអ្នកណាខ្លះ? ឈ្មោះខ្លះ?

ស្រល់៖ វាច្រើនតែក្មេងតូចៗ ចូលការពារហើយវាងងុយដេកទៅ ហើយអ្នកទោសធ្វើសកម្មភាព បានទៅ ។

វីរះ ៖ អាយុប្រហែលប៉ុន្មានឆ្នាំ?

ស្រល់៖ ១៥-១៨ ។

វីរះ ៖ ហ្នឹងហ៊ីគាត់ចាប់ផ្ទាល់ឬមួយយ៉ាងម៉េច? បញ្ជាឲ្យកូនចៅចាប់យកទៅ?

ស្រល់៖ កូនចៅហ្នឹង ។

វីរះ ៖ តែហ៊ីហ្នឹងអ្នកបញ្ជា?

ស្រល់៖ ចេញបញ្ជាពីគាត់មក ។

វីរះ ៖ តែអាចឹងៗញឹកញាប់ទេអ្នកយាមគុកត្រូវគេដាក់ទោសចឹង?

ស្រល់៖ មិនសូវមានដែរទេ ។

វីរះ ៖ តែបើមានត្រូវតែដាប់គុកចឹងហ្មង?

ស្រល់៖ មានត្រូវតែដាប់ហ្មងមិនថាអ្នកណាជាអ្នកណា ។

វីរះ ៖ ហើយដាប់ហើយសួរថាតើអ្នកហ្នឹងរស់ឬក៏ស្លាប់?

ស្រល់៖ ងាប់ ។

វីរះ ៖ ដឹងថាស្លាប់ចឹងហ្មង ។ ស្លាប់គេសំលាប់នៅមន្ទីរហ្នឹងឬគេដឹកទៅសំលាប់នៅក្រៅ?

ស្រល់៖ សំលាប់ចោលនៅកន្លែងហ្នឹងហ្មង ។

វីរះ ៖ ហ្នឹងពូឃើញផ្ទាល់ដែរ?

ស្រល់៖ ផ្ទាល់ហើយ ។ អ្នកការពារនៅហ្នឹងធ្វើឲ្យគ្រោះថ្នាក់គេសំលាប់នៅមុខហ្នឹង ។

វីរះ ៖ ចឹង ។ ការសំលាប់គេប្រើមធ្យោបាយអីដែរ?

ស្រល់៖ មធ្យោបាយមានតែកាំបិត និងដែកថ្នាំងអំពៅ ។

វីរះ ៖ ដែកថ្នាំងអំពៅចាក់?

ស្រល់៖ វៃ ។

វីរះ ៖ វៃរហូតទល់ស្លាប់ហ្មង?

ស្រល់៖ វៃទល់ងាប់ ។

វីរៈ : ពេលដែលគេសំលាប់ហ្នឹងគេមានសួរពីមូលហេតុអីថាអ្នកណាខុសអីៗ?

ស្រល់: អត់ទេ អត់មានសួរទេ យកទៅសំលាប់ហ្នង ។

វីរៈ : អ្នកណាគេអ្នកដែលវៃអ្នកយាមហ្នឹងដល់ស្លាប់ហ្នឹងពូមានចាំឈ្មោះម្នាក់អីទេ?

ស្រល់: កាលហ្នឹងមានកងវរយ ។

វីរៈ : ឈ្មោះអីដែរ?

ស្រល់: ឈ្មោះប៉េង ។

វីរៈ : ឈ្មោះប៉េងហ្នឹងគាត់ត្រូវបានបញ្ជាពីហឹមក?

ស្រល់: បញ្ជាពីហឹមក ។

វីរៈ : ក្រៅពីប៉េងហ្នឹងមានអ្នកណាទៀត?

ស្រល់: ក្រៅពីហ្នឹងអត់មាន គេដោយខ្លួន មុខការងារគេដោយខ្លួន ក្រៅពីហ្នឹងងាប់អស់បាត់ហើយ ។

វីរៈ : ស្លាប់បាត់ហើយ ។ ទើបតែស្លាប់ពេលយើងឥឡូវៗនេះតើហ្អី?

ស្រល់: ទើបតែស្លាប់ពេលយើងមុនចចារគ្នាត្រូវ ។

វីរៈ : ស្លាប់ដោយសារអីគេ?

ស្រល់: ត្រូវគ្រាប់បែក ។

វីរៈ : ចុះអ្នកដែលគេសំលាប់ហ្នឹងពូមានចាំឈ្មោះទេ មានស្គាល់ឈ្មោះ គេមានប្រាប់ឈ្មោះអីទេ?

ស្រល់: ឈ្មោះ...យើងនៅជាមួយគ្នាហ្នឹង...ក្នុងមួយអង្គភាពយើង៦នាក់យើងអាចស្គាល់ទាំងអស់ ។ ប៉ុនស្លាប់ទៅ ។

វីរៈ : មានចាំទេ?

ស្រល់: ភ្លេចអស់ហើយ ឈ្មោះច្រើន ត្រឡប់ត្រឡិនពេក ។

វីរៈ : ពូនៅក្នុងហ្នឹងរហូតដល់រយៈពេលថ្ងៃបែកភ្នំពេញហ្នង?

ស្រល់: បែកហ្នង ។

វីរៈ : គេអត់មានដែលដាក់ទុកទណ្ឌកម្មអីទៅលើពូទេ?

ស្រល់: នៅជួនកាលគេដកយើងទៅលត់ដំពិសោធន៍មើលដែរណា ។

វីរៈ : លត់ដំយ៉ាងម៉េច?

ស្រល់: លត់ដំដូចថាគេដកពីការងារស្នូលយើងទៅធ្វើការងារខុសពីហ្នឹងទៅ ដល់យើងធ្វើកើតមិនកើត បានមិនបាន ។

វីរៈ : ការងារអីខ្លះទៅ?

ស្រល់៖ ការផ្សារសព្វមុខទាំងអស់ហ្នឹង ។

## ការស្បែតទី២ ខាង“ក”

វីរៈ៖ ដូចជាធ្វើអីខ្លះ?

ស្រល់៖ ធ្វើបន្ទប់ ធ្វើទ្វារធ្វើបន្ទប់សម្រាប់ដាក់កន្លែងទោសទៀតហ៊ីង ។

វីរៈ៖ អានឹងរយៈពេលយូរទេ គេឲ្យធ្វើអញ្ចឹង?

ស្រល់៖ ហ៊ុ...ធ្វើលត់ដំយើងអញ្ចឹងទៅ អាខ្លះកន្លះខែ អាខ្លះមួយខែទៅ បើយើងអាចថាធ្វើបានធានាបានទៅនៅធ្វើការនឹងទៅ បើថាធ្វើមិនបានដកចេញឲ្យទៅធ្វើស្រែ ។

វីរៈ៖ ដកចេញឲ្យទៅធ្វើស្រែ មិនមែនថាធ្វើមិនបានគេយកទៅសម្លាប់អីទេហ៎?

ស្រល់៖ អត់ទេ ។

វីរៈ៖ ចុះពូញីកញាប់ទេអាគេពិសោធន៍អញ្ចឹង?

ស្រល់៖ ខ្ញុំពិសោធន៍ម្តង ។

វីរៈ៖ ម្តងដែលអត់អីទេហ៎?

ស្រល់៖ អត់អី ។

វីរៈ៖ ឥឡូវពូចាំឈ្មោះថា តើមួយចំនាន់ពូដែលទៅក្នុងស-២១នឹង ពីចេញពីកងពីអីទៅជាមួយពូ នឹងមានចាំឈ្មោះម្នាក់ពីរនាក់ទេ ហើយសព្វថ្ងៃនឹងមានអ្នកណាខ្លះនៅរស់ដែរឬអត់ទេ?

ស្រល់៖ ដូចអត់មាន ឃើញតែផាប់ ។

វីរៈ៖ ឈ្មោះអីគេខ្លះ?

ស្រល់៖ ភ្លេចឈ្មោះហើយ ខ្ញុំឃើញតែរូបថតនៅក្នុងទស្សនាវដ្តីនេះ ហើយឃើញចាំឈ្មោះម្នាក់នៅក្រោមនឹង ហើយនៅរស់ ប៉ុនបច្ចុប្បន្ននេះ មិនដឹងផាប់ឬរស់ឥឡូវនឹង ។

វីរៈ៖ ឈ្មោះអីគេ?

ស្រល់៖ ឈ្មោះ គ័ននោះ ប្រាប់ម៉ិញនឹងណា៎ ។

វីរៈ៖ ខ្ញុំសួរបកទៅពូ បកទៅក្រោយបន្តិចវិញថា គាណាត ពូដឹងដំណើងបន្ទាប់ពីរួចមក គាណាតបាត់ខ្លួនទៅណា៎?

ស្រល់៖ អត់ដឹងទេដល់អញ្ចឹង គាំងពីបែកមកមិនដឹងទៅណា៎មកណើអត់ដឹង ។

វីរៈ តាំងពីដណ្តើមបានមកក៏យ៉ាងម៉េច? តាំងពីវាយចូលភ្នំពេញមកបាត់ដំណឹងគាត់រហូត ឬក៏ទើបតែបាត់ថ្មីៗ?

ស្រល់ៈ ទើបបាត់កាលយើងបែកភ្នំពេញនឹង ។

វីរៈ បែក៧៩ក៏បែក...?

ស្រល់ៈ បែក៧៩យើងនេះនឹង ។

វីរៈ ចុះគ្រែងថាគេចាប់គាត់ហ៊ែតាណាត ចោទថាក្បត់អីណា៎?

ស្រល់ៈ អត់ តាណាតនៅ ។

វីរៈ មិនមែនគេចោទគាត់ថាក្បត់ថាអីទេ?

ស្រល់ៈ អត់ ។

វីរៈ យ៉ាងម៉េចបានពូហ៊ានអះអាងថាអញ្ជឹង ពូជួបគាត់ពេលណាដែរ?

ស្រល់ៈ ព្រោះកាលទៅលិចខ្ញុំអត់ជួបគាត់ទេណា៎ ប៉ុនថាកាលរត់ទៅលិចនៅព្រៃ ហើយដល់នេះខ្ញុំសួរទ័ពដូចគ្នាណាថា ចុះតាណាត តាពិនទៅណាទៅ? គេថាហ៊ឺ...មិនដឹងទៅណាទេ ចេញមកដូចគ្នាហើយ ។

វីរៈ ចេញពីបែកភ្នំពេញហើយដែរនឹង?

ស្រល់ៈ នឹងហើយ ចេញពីភ្នំពេញទៅដូចគ្នាមិនដឹងទៅណាទេ ។

វីរៈ គេនឹងនិយាយប្រាកដឬអត់ទេ អ្នកដែលនិយាយនឹង?

ស្រល់ៈ គេនៅទ័ពដែរ ។

វីរៈ គេនៅជាមួយតាណាតដែរពេលនឹង ឬក៏យ៉ាងម៉េច?

ស្រល់ៈ អានឹងគេនៅទ័ព គេមិននៅផ្ទាល់ជាមួយទេ ព្រោះអ្នកផ្ទាល់ជាមួយ មិនងាយនៅជាមួយគាត់បានទេ ។

វីរៈ គាត់នឹងយ៉ាងម៉េចតាណាតនឹង?

ស្រល់ៈ គាត់ខាងកងពលធំច្រើនបញ្ជាពីក្រោយតើ គាត់ចាំទទួលបញ្ជាពីអគ្គសេនាធិការចេញទៅពីភ្នំពេញទៅចូលគាត់ ចូលគាត់ គាត់បញ្ជាទៅចូលកងទ័ពមុខនោះទៀត អញ្ជឹង តគ្នា ព្រោះគាត់កងពលគាត់ម៉េចនឹងចូលសមរភូមិ បញ្ជាយើងក្នុងសមរភូមិផ្ទាល់ ។

វីរៈ ពេលដែលវៀតណាមវាយចូល ដូចជាអ្នកនៅក្នុងគុកក្នុងអីនឹង អ្នកយាមគុកយាមអីនឹងយ៉ាងម៉េចទៅពេលហ្នឹង ដូចជាពូអីណា៎ បែកដូវគ្នារត់ ឬមួយយ៉ាងម៉េច?

ស្រល់ៈ បែកដូវគ្នា នាំគ្នារត់ ។

វីរះ៖ ចុះដូចខុច ពេលភ្ជាមៗខុចទៅណា?

ស្រល់៖ រត់ទៅលិចទាំងអស់ ។

វីរះ៖ គេមានប្រកាសឲ្យរត់ទៅតាមអត់ឬទេ?

ស្រល់៖ គេឲ្យយើងទៅ ទៅជាមួយគ្នានឹង ចេញទៅជាមួយគ្នានឹង ។

វីរះ៖ ពេលឆ្នាំពួរត់នឹងណា ពេលឆ្នាំ៧៩វៀតណាមចូលនឹង សួរថានៅក្នុងគុកនឹងអ្នកទោសសល់គ្នាប្រហែលជាប៉ុន្មាននាក់ដែលនៅរស់?

ស្រល់៖ នៅ បើអ្នកជាប់គុកនៅក្នុងហ្នឹង ងាប់ទាំងអស់ រស់តែអ្នក... ។

វីរះ៖ ជាងគូជាងអីនឹង?

ស្រល់៖ ជាងគូគំនូរនៅ ។

វីរះ៖ ឈ្មោះអីគេខ្លះ?

ស្រល់៖ ខ្ញុំអត់ស្គាល់ឈ្មោះគាត់ទេ ។

វីរះ៖ តាណាគគូររូប បូ ម៉េង តាមួយរៀនទាបនឹង ដែលឃើញទេ?

ស្រល់៖ ឃើញ គូររូបគូរអីនឹង នៅមួយក្រុមគាត់នឹង ព្រោះគេដោះលែងគាត់ គាត់អ្នកគូររូប ហើយមួយនោះអ្នកចាក់រូប ខ្ពស់ ស្តើងខ្ពស់ស មិនដឹងអី មិនដឹងនៅមិននៅ ប៉ុននឹងទៅជាមួយខុចទាំងអស់ណា ។

វីរះ៖ អញ្ចឹង នឹងរត់ទៅជាមួយតាខុចនឹងដែរ?

ស្រល់៖ នឹងហើយទៅជាមួយតាខុចទាំងអស់ ។

វីរះ៖ យ៉ាងម៉េច បានខុចពេញចិត្តពួកគាត់នឹង ឬមួយយ៉ាងម៉េច?

ស្រល់៖ គាត់នឹង តាខុចនឹងគាត់អ្នកចេះ ដល់ហើយមកខាងអ្នកទោសដែលដោះលែងឲ្យធ្វើការនឹងក៏សុទ្ធតែជាអ្នកធ្វើការទាំងអស់គ្នា ដល់អញ្ចឹង មិនដឹងយ៉ាងម៉េច គាត់ទុកប្រើអញ្ចឹងទៅ ។

វីរះ៖ អញ្ចឹង គាត់អ្នកគូរអ្នកអីនឹង សុទ្ធសឹងតែជាអ្នកទោសទេហ៎?

ស្រល់៖ អ្នកទោសនឹង ។

វីរះ៖ មកដោយសារដឹងថាគាត់ចេះគូរចេះប្រើការកើត គេទុកទៅ?

ស្រល់៖ នឹងហើយទុកទៅ ។

វីរះ៖ អញ្ចឹងពេលបែកនឹងអ្នកទោសស្លាប់ទាំងអស់ នៅសល់តែពួកគាត់ប៉ុន្មាននាក់នឹង?

ស្រល់៖ នឹងហើយនៅតែប៉ុន្មាននាក់នឹងទេ អ្នកនៅក្រៅនឹងទេ ទៅជាមួយតាខុចនឹងទៅលិចទៅ ទៅជាមួយគ្នានឹងទៅ ខាងត្បូងនឹងទៅ ។

វីរះ   ហើយកាលជំនាន់ហ្នុ៎ង ពូដែរនិយាយស្ដីជាមួយឌុចជាមួយហ៊ានឹងដែរឬអត់ទេ?

ស្រល់៖ និយាយគ្នាធម្មតា ជួបគ្នានិយាយគ្នា ។

វីរះ   ស្គាល់ឈ្មោះគ្នាទៅវិញទៅមកដែរឬអត់ទេ?

ស្រល់៖ ស្គាល់ ។

វីរះ   គាត់ហៅពូថាម៉េចដែរ?

ស្រល់៖ គាត់ហើយយើងតែមិត្តៗអញ្ចឹងទៅ ។

វីរះ   អញ្ចឹង មិត្តៗហ៎ែ?

ស្រល់៖ ហ៊ឺ...ហើយយើងហៅគាត់តែបងៗអញ្ចឹងទៅ ។

វីរះ   ចចារផ្ទាល់និយាយផ្ទាល់ហ្នឹងហ៎ែ?

ស្រល់៖ បាទ និយាយដូចអញ្ចឹង និយាយទៅមកៗនឹង ហូបបាយជាមួយតែគ្នានឹងទៅ ។

វីរះ   ចុះដូចថាតាមរយះការរស់នៅជាមួយគាត់ គិតថាគាត់ចិត្តដាច់ ដូចថា ដូចសួរពីមុនមក អញ្ចឹងថាចង់បានពត៌មាន គាត់សុទ្ធចិត្តធ្វើបាបធ្វើអីអញ្ចឹង?

ស្រល់៖ គាត់ធ្វើនេះអញ្ចឹង គាត់ថាធ្វើនេះអញ្ចឹង គាត់ថាយ៉ាងម៉េចគឺអញ្ចឹងហើយ មិនចាំថាអ្នកទោសទេទេ ត្រឹមតែកូនទាហានគាត់ក៏ដោយ តែគាត់បញ្ជាឲ្យឃឹតឃាវហើយ គឺដៃជើងហើយ អាណានឹងគេហៅថាហាត់ណា៎ ហាត់ឲ្យរហ័សរហួន ។

វីរះ   ឥឡូវខ្ញុំសួរពូបន្ថែមទៀតថា ពី៧៥រហូតដល់៧៩នឹង ចាប់តាំងពីខ្មែរក្រហមគ្រប់គ្រងនឹងសួរថាគួរនៅប៉ុន្មានកន្លែង ធ្វើការនៅប៉ុន្មានកន្លែង?

ស្រល់៖ អានឹង៧៥មកហ៎ែ?

វីរះ   បាទ តាំងពីពេលដែលពូវាយចូលភ្នំពេញមកហើយ ចាត់តាំងឲ្យពូចូលធ្វើការ ចាត់តាំងឲ្យពូទៅធ្វើការចូលតាមស-២១នឹង រហូតដល់បែកវៀតណាមចូលពូរត់មក រត់វៀតណាមទៅលិចទៅអីនឹង?

ស្រល់៖ ទៅមួយកន្លែងនឹង នៅតែនឹង ។

វីរះ   តែមុនៗនឹងទៅស្វាគូ?

ស្រល់៖ មុននឹងនៅទ័ពនឹង ។

វីរះ   នៅស្វាគូ ពូថានៅស្វាគូ?

ស្រល់៖ ស្វាគូនឹង អានឹងនៅក្នុងទ័ពហើយណា៎ មិនទាន់ចាត់តាំងទេណា ។

វីរះ   បាទ ក្នុងទ័ពតែ៧៥ហើយហ៎ែ?

ស្រលៈ អានឹងនៅក្នុងដើមឆ្នាំ៧៥ ទេណា៎ ។

វីរៈ បាទ អានឹងខ្ញុំចង់និយាយពី៧៥មកទេ?

ស្រលៈ អានឹងទៅធ្វើស្រែចំការខ្លះ ធ្វើបាន២ខែនឹងបានដកមកវិញបាននៅក្នុងភ្នំពេញនឹងរហូតនឹងចូលស-២១នឹងរហូតបណ្តោយ ។

វីរៈ ចុះអ្នកនៅក្នុងទួលស្លែងទាំងអស់នឹងដែរគេចាប់មកនឹង សុទ្ធសឹងតែជាអ្នកប្រភេទយ៉ាងម៉េចខ្លះ? ជាអ្នកមានបណ្តាស័ក្តពីមុនមក អ្នកជាប់ពាក់ព័ន្ធ ឬក៏ជាខ្មាំង ឬក៏ជាអី?

ស្រលៈ ច្រើនស្រទាប់ ។

វីរៈ មានស្អីខ្លះ ប្រភេទស្អីខ្លះ?

ស្រលៈ ច្រើនតែអ្នកទ័ពធ្វើការជំនាន់ប៉ុល ពតនឹង ។

វីរៈ ជំនាន់ប៉ុល ពត?

ស្រលៈ អ្នកធ្វើការពីសង្គមមកអត់មានទេ ។

វីរៈ អ្នកដែលប៉ុល ពតដែលគិតថាអាចចោទថាជាខ្មាំងអីអញ្ចឹងនឹងហែ៎? ខ្មាំងយួនខ្មាំងអី?

ស្រលៈ នឹងហើយ គេស្រាវជ្រាវតាមឯកសារមក យើងជាប់ពាក់ព័ន្ធខ្មាំងខ្សែរយៈអីនឹងមក បើការនៅជាមួយពួកប៉ុល ពតនឹង មានតែពួកនឹងទេណា៎ ហើយត្រង់ថាពួកមកពីសង្គមចាស់ពីមុនមក... ។

វីរៈ អញ្ចឹង កាហេរ្យបេ, សេអ៊ីអាអីជាមុខសញ្ញាយកមកដាក់គុកដែរឬអត់ទេ អ្នកដែលមានពាក់ព័ន្ធខ្សែនឹងណា៎ ប្រវត្តិរូបដែលមានពាក់ព័ន្ធអញ្ចឹង?

ស្រលៈ យក ។

វីរៈ អញ្ចឹង នៅក្នុងគុកនឹង មិនមែនមានតែអ្នកធម្មតាប្រជាជនសាមញ្ញអីយកទៅដាក់អីទេហែ៎?

ស្រលៈ អត់ទេ ។

វីរៈ សុទ្ធតែអ្នកទោសនយោបាយទោសអីទេ?

ស្រលៈ នយោបាយទាំងអស់ ។

វីរៈ អញ្ចឹង តាំងពី៧៥ដល់៧៩នឹង ពូដែលឃើញគេធ្វើបាបក្មេងៗអីដូចថា បង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរអីដែរឃើញទេ?

ស្រលៈ អត់មានទេហ្នុ៎ង អត់មាននៅនោះ ។

វីរៈ អត់ដែលឃើញទេ?

ស្រលៈ អត់មាន តែចេញឆ្ងាយនឹងមិនបានដើរចេញឆ្ងាយផង នៅតែក្នុងបរិវេណនឹង បើថាមួយ គឺឡូប្អូនជ្រុងនឹង យើងមានសិទ្ធិតែនៅមួយគឺឡូប្អូនជ្រុងនឹង ។

វីរៈ ចុះដូចជាការបំផ្លេចបំផ្លាញអីផ្លូវថ្នល់ផ្លូវអីនឹង វត្តអារាមអីដែលឃើញទេ?

ស្រលៈ អត់ អត់ដែលចេញ បើកន្លែងអត់ដែរចេញពីកន្លែងផង ។

វីរៈ ចុះពូ ពេលដែលពូចេញពីស-២១នោះ ពូរត់ទៅតាមផ្លូវណាទៅ?

ស្រលៈ ទៅលិចទៅឆ្លងកាត់ផ្លូវជាតិលេខ២ លេខ៣ លេខ៤ ឆ្ពោយទៅដល់ឱរ៉ាល់នោះ ។

វីរៈ ទៅដល់ឱរ៉ាល់ ទៅដល់ហ្នឹង រយៈពេលយូរដែរឬអត់ទេ?

ស្រលៈ ទៅយូរ ។

វីរៈ ទៅធ្វើអីនៅហ្នឹង?

ស្រលៈ រត់ទៅ គេចពីយួនរត់វាយចូលមកនឹង ទ័ពអីទាំងអស់គ្នានឹងរត់ទៅនោះទៅ ។

វីរៈ អញ្ចឹង ទាំងអ្នកយាមគុកទាំងអ្នកសួរចម្លើយ អ្នកដែលធ្វើការនៅក្នុងគុកនឹង មិនមែនអ្នកទោសទេណា ពេលបែកនឹងហើយ នៅសល់គ្នាប្រហែលជាប៉ុន្មាននាក់? នៅទាំងអស់ ឬក៏មានបាត់ខ្លះ ។

ស្រលៈ នៅទាំងអស់គ្នានឹង នៅទាំងអស់គ្នា ប៉ុនដល់ពេលរត់ចេញទៅបាត់គ្នាអស់ទៅ រត់ព្រះអាយុ៉សរៀងខ្លួននឹង ។

វីរៈ មានអ្នកណាគេដឹកនាំរត់ ឬក៏យើងនាំគ្នារត់តែផ្ទាល់ៗខ្លួននឹង ។

ស្រលៈ អត់មានទេ ទៅយកព្រះអាយ៉ោសរាងៗខ្លួន រត់យកតែមួយរូបខ្លួននឹង គេក៏តាមយើង យើងក៏តាមគេនាំគ្នាទៅនឹង ទៅដល់នោះបានប្រមូលគ្នាវិញ បានប៉ុន្មានយកប៉ុណ្ណឹងទៅ ។

វីរៈ ចុះការហូបចុកហូបអីពូ ពូធ្វើការនៅក្នុងនឹង គេឲ្យហូបចុកយ៉ាងម៉េច?

ស្រលៈ ហូបចុកធម្មតា ។

វីរៈ គ្រប់គ្រាន់ទេ?

ស្រលៈ បរបូ គេបំប៉នបរបូរណាស់ ។

វីរៈ ចុះអ្នកទោស?

ស្រលៈ អ្នកទោសខ្វះខាត ។

វីរៈ អើ...នៅក្នុងគុកនឹង ដូចថានៅពេលដែលគេដាក់ទ្រុងដាក់អីយកទោសម្ចាប់នឹងណា ពូដឹងកន្លែងដែលគេយកទោសម្ចាប់នឹងដែរឬអត់?

ស្រលៈ អត់ទេ មិនដឹងយកទៅណាទេ មិនដឹងយកទៅណា យកទៅយប់មិនដឹងទៅណា ។

វីរៈ   តែពូមានដែលស្តាប់បានដូចថាពីអ្នកណាមួយ ដូចថាអ្នកធ្វើការជាមួយគ្នាអីអញ្ចឹង មកខ្សឹបប្រាប់ពូតថា ហ៎...ខុច ឬក៏ហ៊ីនេះ គាត់មានគោលនយោបាយថាអ្នកណាដែលធ្វើខុស អ្នកណាដែលមកសួរចម្លើយហើយត្រូវតែយកទៅសម្លាប់ចោលនឹង មានដែលឮអាពាក្យនឹងទេ?

ស្រល់៖ អត់មានឮនិយាយ ស្ងាត់ឈឹងហ្នឹង តែគ្រាន់តែថាដល់ពេលចេញយកទៅសម្លាប់ចោល យកសៀវភៅមកគេមើលសៀវភៅនឹង ហើយគេដើរប្រាប់យើងតាមមុខសញ្ញា យើងយាមចាក់ ដាក់ខ្នោះឲ្យគេនឹង គេយកទៅរុយទៅបាត់ទៅ ។

វីរៈ   អើពេលរត់ទៅតាមផ្លូវជាតិ លេខ៣លេខ៤អី មានជួបខាងកងទ័ពខាងអីទៀតទេ?

ស្រល់៖ អឺ...វាងរហូត អត់មានជួបគ្នាទេ ។

វីរៈ   យើងអត់ឲ្យជួបឬក៏យើងរត់គេចហ្នឹង?

ស្រល់៖ ជួបក៏គេចដែរ ។

វីរៈ   ខាងវៀតណាម ខាងកងទ័ពខ្មែរក្រហមអីមាននៅមានទេ?

ស្រល់៖ មានតើ ខ្មែរក្រហមនឹងរត់ទៅនឹង ទ័ពទៅជាមួយគ្នានឹង ខ្មែរក្រហមទៅជាមួយគ្នាទាំងអស់ អត់មានអីទេ ។

វីរៈ   ចុះទៅឱរ៉ាល់នឹង ពូស្នាក់នៅឱរ៉ាល់នឹងហ្នឹង ឬក៏យ៉ាងម៉េច?

ស្រល់៖ នៅ ខាងកើតឱរ៉ាល់នឹងបន្តិច ។

វីរៈ   ពូឈប់ធ្វើអីគេនៅហ្នុំង?

ស្រល់៖ ឈប់សម្រាកនៅហ្នុំង ទៅដល់សម្រាកហ្នុំង ប្រមូលគ្នាវិញ ។

វីរៈ   ប្រមូលគ្នាវាយ...?

ស្រល់៖ ប្រមូលគ្នាហើយបានកម្លាំង បកមកក្រោយវាយវិញទៀត ។

វីរៈ   អញ្ចឹង ពូបានមកវាយ បកមកវាយវិញទៀត?

ស្រល់៖ បកមកវាយវិញនឹង បានបានមកផ្ទះវិញរហូតបណ្តោយនឹង ។

វីរៈ   វាយអត់ឈ្នះក៏យ៉ាងម៉េច បានបកមកផ្ទះ?

ស្រល់៖ វាយមកវាយមិនឈ្នះ កម្លាំងយើងវាអត់ទៅៗ ហើយណាមួយស្បៀងយើងមិនសូវមាន អញ្ចឹង យូរៗយើងបណ្តោះខ្លួនមកផ្ទះវិញមក ។

វីរៈ   យើងចាញ់ស្បៀងហ៎?

ស្រល់៖ ចាញ់ ។

វីរៈ   ហើយកាលហ្នុំង ប្រមូលកម្លាំងបានច្រើនទេ?

ស្រល់៖ កម្លាំងច្រើន ។

វីរៈ៖ កម្លាំងប្រហែលជាប៉ុន្មាន?

ស្រល់៖ ចូលចង់រាប់ម៉ឺនន៎ ។

វីរៈ៖ កម្លាំងពេលនឹងរាប់ម៉ឺនដែរពេលហ្នុ៎ងហេ៎?

ស្រល់៖ កម្លាំងមូលគ្នាទាំងអស់ឡើងដូចផ្សិតក្នុងព្រៃ ។

វីរៈ៖ មកពីខាងណាខ្លះ?

ស្រល់៖ មកវាយបែកបាក់ពីស្វាយរៀងម្ល៉េះ ទៅ ទៅមូលគ្នាក្នុងព្រៃទាំងអស់នឹង ទ័ពប៉ុន្មានអីប៉ុន្មាន គេមូលគ្នាក្នុងព្រៃទាំងអស់នឹង ។

វីរៈ៖ កាលហ្នុ៎ងនៅមូលនៅដុំណា៎?

ស្រល់៖ នៅគ្រប់ទាំងអស់ ។

វីរៈ៖ ដូចថាកន្លែងដែលទីតាំងធំហ្នឹងណា៎ នៅណា៎?

ស្រល់៖ មិនទៀងទេ ។

វីរៈ៖ ដូចស្បៀងអីបានពីណាមកកាលហ្នុ៎ង?

ស្រល់៖ ស្បៀងរកខ្លួនឯង តាមផ្ទះប្រជាជន ។

វីរៈ៖ កាលហ្នុ៎ង ដូចថាមានការដឹកនាំរបស់អ្នកណាគេមួយទៀតទេ ដូចថាអ្នកដែលដឹកនាំបកទៅវាយវិញនឹង ពូមានចាំទេ អ្នកណាគេដែលដឹកនាំធំនឹង?

ស្រល់៖ អត់ទៀង ដល់ទៅលិចអញ្ចឹង អ្នកដឹកនាំប្របូកប្របល់គ្នាច្រើនណាស់ ។

វីរៈ៖ ចុះដូចជាអ្នកធំៗប៉ុន្មាននាក់ដែលដូចជាអ្នកធំៗជំនាន់ហ្នុ៎ង ដូចជាប៉ុល ពត, អៀង សារី, ខៀវសំផន, នួន ជា, ឌុចអីនឹងយ៉ាងម៉េចដែរ នៅជុំគ្នានឹងដែរឬក៏យ៉ាងម៉េចដែរឬមួយយ៉ាងម៉េច?

ស្រល់៖ អានឹងបែកគ្នាហើយ បែកគ្នាអស់រលីង ។

វីរៈ៖ ចុះថានៅទ័ពៗនឹង?

ស្រល់៖ ទ័ពៗតែត្រឹមអាដូចថាវរសេនាតូច មួយវរសេនាធំអី ជួបជុំគ្នា គេប្រមូលៗគ្នាទៅណា៎ ។

វីរៈ៖ ចុះដូចថាមានការបញ្ជា មានការបំផុសបំផុលពីមេធំៗឲ្យប្រមូលអញ្ចឹង ឬគ្រាន់តែយើងជាវរសេនាធំ វរសេនាតូចអី?

ស្រល់៖ យើងវរសេនាធំ វរសេនាតូចនឹង យើងប្រមូលគ្នាយើងនឹង ហើយមេនឹងអ្នកធំៗនឹងមិនដឹងនៅណាហ្នឹងផង រត់ទៅមុនបាត់មិនដឹងនៅណាផង ។

វីរះ  ហើយបាយវាយដាមួយវៀតណាមប៉ុន្មានដងទៀតមុនពេលពូមកដល់ផ្ទះ?

ស្រល់ៈ ហ៊ឺ...វាយប៉ែហូរតែរហូត ។

វីរះ  តាមផ្លូវរហូតដែរ?

ស្រល់ៈ តាមផ្លូវរហូត ជួបកន្លែងណាវាយកន្លែងនឹង ។

វីរះ  តែមានចាញ់មានឈ្នះ?

ស្រល់ៈ ចាញ់ឈ្នះៗ ធម្មតានឹង ដល់មើលទៅសេដ្ឋកិច្ចដាច់អស់រលីងទៅ ។

វីរះ  បែងជួរទៅ?

ស្រល់ៈ បែរជួរទៅ រត់ទៅផ្ទះទៅ ។

វីរះ  ពូមកតាមផ្លូវណាមកដល់ស្រុកភូមិ?

ស្រល់ៈ មកតាមភ្នំតាម៉ៅ ។

វីរះ  ភ្នំតាម៉ៅបុករហូតមកនេះមក អ៊ូ...ដូចពូផុសដែរខ្ញុំសួរម្សិលមិញ ម្សិលមួយថ្ងៃដែរ គាត់មកពីខាងភ្នំតាម៉ៅដែរ ។

ស្រល់ៈ ចេញមកតែច្រកនឹងទេ ច្រកភ្នំតាម៉ៅនឹង ។

វីរះ  ហើយរយះពេលប៉ុន្មានគាំងពីការធ្វើដំណើររត់មក ហើយវាយដាមួយវៀតណាមរហូតមកដល់ផ្ទះរយះពេលប៉ុន្មានបានមកដល់ផ្ទះ?

ស្រល់ៈ យូរដែរ ។

វីរះ  មកដល់ស្រុកឆ្នាំ៧០ប៉ុន្មានហ៉ែ? ៨០ក៏៧០?

ស្រល់ៈ មកដល់៨០ហើយនឹង ចូល៨០ទៅហើយ ទៅមួយឆ្នាំដែរបានបានមកដល់ផ្ទះវិញ ។

វីរះ  ចុះពូយល់ថាកាលជំនាន់ហ្នុ៎ង តើពូគិតថាគួរទម្លាក់បន្ទុកទៅលើអ្នកណាគេដែលមានការសម្លាប់មនុស្ស? ពូគិតថាជំនាន់ហ្នុ៎ង មានការសម្លាប់មនុស្សនៅតាមសហករណ៍នៅតាមភូមិឃុំដែរឬអត់?

ស្រល់ៈ អត់ដឹង ខាងក្រោយអត់មានដឹងថាតាមសហករណ៍តាមអីស្លាប់ច្រើនណា៎ អត់មានដឹងសុទ្ធទាល់មកដល់ ផ្ទះលើសួរគេនិយាយថាស្លាប់ច្រើន ។

វីរះ  មកតាមផ្លូវមានឃើញឆ្អឹងឃើញអីពេញទេ?

ស្រល់ៈ ដល់មកតាមផ្លូវនឹងមាន ឃើញអាដែងឆ្អឹងខ្មោចមនុស្សយើងងាប់ វាគ្នា អាពេលវាយគ្នាសមរភូមិនឹងណា៎ ហើយត្រង់ថាតាមប្រជាជនយើងដែលគាត់ស្លាប់នៅតាមសហករណ៍នេះអត់មានឃើញទេ ។

វីរៈ   ពូអត់មានដែលដឹងពីសុខទុក្ខ ពីឪពុកម្តាយបងប្អូនទេ?

ស្រល់៖ គ្មាន ។

វីរៈ   អត់ដែលបានមកលេងផ្ទះអីទេ?

ស្រល់៖ អត់សុទ្ធ តាំងពីចេញពីផ្ទះទៅរហូត មិនដែលវិលមកផ្ទះបានមួយថ្ងៃទេ ។

វីរៈ   អត់មានគិតសុំគេមកលេងឬមួយក៏គេមិនឲ្យមក?

ស្រល់៖ គេថាឲ្យមកដែរ ប៉ុនដូចថាការងារនឹងវាច្រើនពេកទៅ អារឿងភ្នំពេញមកដល់នេះគេឲ្យមកលេងផ្ទះដែរប៉ុនគេគ្រាន់តែប្រាប់ថា ឥឡូវចាំមើលរៀងស្បើយបន្តិចទៅ ចាំឲ្យទៅលេងផ្ទះទៅឡានទៅអីទៅគេជូនទៅ ។

វីរៈ   ចុះមកដល់សព្វថ្ងៃនេះពូមើលត្រឡប់ទៅក្រោយវិញណា៎ គិតថា មកដល់ផ្ទះហើយ បានដឹងថាមានការសម្លាប់មនុស្សច្រើនហួរហែរអញ្ចឹង តាមគំនិតពូ ពូគិតថាជាការទទួលខុសត្រូវរបស់អ្នកណាគេដែលជាអ្នកធ្វើឲ្យមានការសម្លាប់មនុស្សនឹង ត្រឹមតែថ្នាក់ឃុំ ភូមិឃុំជាអ្នកទទួលខុសត្រូវ ឬក៏ជាថ្នាក់ស្រុក តំបន់ ភាគ ឬក៏មេដឹកនាំធំៗខាងលើ?

ស្រល់៖ នឹងបើតាមខ្ញុំនោះ ខ្ញុំនៅកន្លែងខ្ញុំនោះហ្នង រៀននោះហ្នងអីហ្នង ហើយខ្ញុំភ្លាប់បាន បើនិយាយពីរឿងសម្លាប់វិញ ខ្ញុំមិនចោទទៅដល់ថាប៉ុល ពតបញ្ជាមកប៉ុន្មានទេ ប៉ុល ពតបញ្ជាមកដែរ ប៉ុនគាត់បញ្ជាមកតែកន្លែងទំពាកន្លែងអីផ្សេងទេ បើការសម្លាប់តាមភូមិតាមឃុំក្នុងយើងនេះគឺមកពីបញ្ជាពីស្រុកយើងក្រោមនេះ នឹងបើតាមខ្ញុំភ្លាប់មើល ។

វីរៈ   អញ្ចឹង បានន័យថាការសម្លាប់ខ្លះ វាអាចតែកើតមាននៅតាមភូមិឃុំយើងសុទ្ធ អ្នកធ្វើខ្លួនឯងនឹងមិនបានទទួលបញ្ជាពីថ្នាក់លើមកទេ?

ស្រល់៖ នឹងហើយ មិនបានទទួលទេ ។

វីរៈ   តែអាចមានខ្លះទទួលបញ្ជាដែរ?

ស្រល់៖ នឹង ខ្លះទទួលបញ្ជាមកពីខាងលើ ។

វីរៈ   អញ្ចឹង ពូយល់ថាអញ្ចឹង តាមការភ្លាប់បានរបស់ពូការជំនាន់ហ្នុ៎ង?

ស្រល់៖ ព្រោះខ្ញុំនៅហ្នុ៎ង ខ្ញុំភ្លាប់បានច្បាប់អីចេញពីនោះណា៎ ។

វីរៈ   ច្បាប់ចេញមកយ៉ាងម៉េច?

ស្រល់៖ នឹងហើយច្បាប់ខ្ញុំនៅនោះ ចេញពីកន្លែងខ្ញុំមកនោះអញ្ចឹង ។

វីរៈ   និយាយថាម៉េច ពូអាចជួយនិយាយប្រាប់...?

ស្រល់ៈ ចេញមកពីនោះមក ច្បាប់ចេញមកពីមកនឹង អត់មានរឿងថា ខាងក្រោមនេះឲ្យតឹង តាំងពីបន្ទត់បាយបន្ទត់អី អត់មានទេ គឺឲ្យធ្វើមកត្រឹមត្រូវស្រួលបួលណា៎ ឲ្យធ្វើអញ្ចឹង ប៉ុនមកក្រោយនេះពួសួរថាសម្លាប់ច្រើន ពួសួរតែអត់ពួសួរតែអី ខ្ញុំចាំមើល ខ្ញុំស៊ើបអង្កេតមើល ទៅដល់ពិនិត្យមើលទៅ មកពីស្រុកប្រលងប្រណាំងគ្នា ចង់យកស្នាដៃ ចង់យកបុណ្យសក្តិ ចង់យកបុណ្យសក្តិ បានសមរភូមិខាងក្រោយនឹង សហករណ៍ សហអីនឹងស្លាប់ច្រើន ខ្ញុំស្រាវជ្រាវរកទៅឃើញអញ្ចឹង ។

វីរៈ ពូមានឯកសារអីណា៎ដែលបញ្ជាក់ថាមានការប្រលងប្រណាំងគ្នាថ្នាក់ស្រុកថ្នាក់អី ចង់បានបុណ្យសក្តិអីទេ?

ស្រល់ៈ អានឹងព្រោះចម្លើយដែលចាប់យកទៅអ្នកធ្វើការត្រឹមស្រុកឡើងទៅ គេសួរចម្លើយទៅ ហើយគេច្រើននិយាយអីគ្រប់គ្នា ។

វីរៈ អញ្ចឹង ពេលគេចាប់យកទៅសួរចម្លើយនឹង គេសួរថាយ៉ាងម៉េច គេសួរថាយ៉ាងម៉េច?

ស្រល់ៈ គេសួរទៅ ដល់នេះឆ្លើយថា ការសម្លាប់ប្រជាជននឹងមកចង់យកគុណសម្បត្តិ ដូចថាខ្ញុំធ្វើគណៈស្រុកអញ្ចឹង ខ្ញុំចង់បានគុណសម្បត្តិដើម្បីខ្ញុំចង់ឡើងទៅគណៈខេត្តទៀត អញ្ចឹង ខ្ញុំរាយការណ៍មួយស្រុកខ្ញុំនឹងឲ្យមានគុណសម្បត្តិច្រើនទៅ ប្រជាជនខ្ញុំបរបូរគ្រប់គ្រាន់នឹងទៅ នឹងអត់មានសម្លាប់មានអីអញ្ចឹងទៅ ខ្ញុំឡើងទៅទៀតទៅអញ្ចឹង ដល់គេមកស៊ើបការណ៍មកស្រាវជ្រាវមើលទៅអ្នកឯងបន្ទត់ប្រជាជននេះ៎ ហើយចង់យកគុណសម្បត្តិ ហើយដូចថាយើងធ្វើស្រូវនឹងផ្តល់ឲ្យរដ្ឋច្រើនទៅ ឡើងបុណ្យឡើងសក្តិអីនោះ អាកន្លែងនឹងអញ្ចឹងតើ ។

វីរៈ ពេលដែលគេថាសួរនឹង សួរនៅណានៅស-២១នឹងក៏ម៉េច?

ស្រល់ៈ ស-២១នឹង ។

វីរៈ អញ្ចឹង គេអាចសួរចម្លើយថានៅស្រុកភូមិអ្នកឯងមានការសម្លាប់មនុស្សអីអញ្ចឹង ឬមួយក៏គេសួរយ៉ាងម៉េចផ្សេងទៀត?

ស្រល់ៈ អានឹងគេសួរដំណើរតាមខ្សែបណ្តាញគេមកពីលើមក តាំងពី ធម្មតាយើងមកចាប់មួយៗទាល់តែមានខ្សែបណ្តាញក្បត់មកបានចាប់បានណា៎ ។

វីរៈ អញ្ចឹង ក៏ធ្លាប់គណៈស្រុកអីនឹងឆ្លើយថាដោយសារគុណសម្បត្តិអីអញ្ចឹងដែរ បានមានការសម្លាប់ មានការប្រកួតប្រជែង ការប្រកួតប្រជែងៗរវាងស្រុកនឹងស្រុក?

ស្រល់ៈ នឹងហើយ ប្រកួតប្រជែងគ្នាដើម្បីយកគុណសម្បត្តិនឹងណា៎ ។

វីរៈ អញ្ចឹង ពូគិតថាវាជាការទទួលខុសត្រូវរបស់ថ្នាក់លើដែរ ព្រោះអ្នកនឹងជាអ្នកដឹកនាំគេ គួរតែ...?

ស្រល់ៈ អើ...អានឹងវាគ្រាន់ថាមួយចំណោមនឹងវានៅអ្នកយើងទទួលខុសត្រូវធំជាងគេនឹង ទោះបីយ៉ាងម៉េច ក៏ត្រូវទទួលដែរ ។

វីរៈ គិតថាឥឡូវការធ្វើស្រែ ដូចថាការបញ្ជាអីមួយ ការឲ្យធ្វើអីមួយ សួរថាឥឡូវថ្នាក់លើបញ្ជាឲ្យថ្នាក់ក្រោមធ្វើអញ្ចេះ ហើយគិតថាថ្នាក់លើនឹងបញ្ជាហើយមិនចាំទទួលយកលទ្ធផល ឬក៏គ្នាំមើលថ្នាក់ក្រោមទេ ឬក៏គាត់ចុះមកមើលផ្ទាល់យករបាយការណ៍យកអីដែរ? អានឹងត្រូវតែថ្នាក់លើ?

ស្រល់ៈ អានឹងត្រូវតែថ្នាក់លើហើយ គេមកយក ប៉ុនថាយើងបញ្ជាមក ប៉ុននៅទទួលអារបាយការណ៍សព្វមុខនឹងទៅ ហើយចេះតែជឿៗគេទៅ វាទៅមួយដំណើរទៅ ។

វីរៈ អញ្ចឹង បានន័យថាគាត់ជឿ ដូចថាមិនបានចុះមកដិតដល់?

ស្រល់ៈ មិនចុះមកផ្ទាល់ណា៎ ។

វីរៈ តែគំនិតពូគិតថា ទោះបីយ៉ាងណាក៏យើងជាមេដឹកនាំក៏ត្រូវតែទទួលខុសត្រូវដែរ?

ស្រល់ៈ ត្រូវតែទទួលអញ្ចឹង ព្រោះជាកំហុសរបស់យើង ព្រោះយើងអ្នកដឹកនាំធំជាងគេហើយ ។

វីរៈ ចុះដូចថាតាមរយៈកាលសម្រាប់ការអីអញ្ចឹង ពូគិតថាគួរគាំទ្រឲ្យមានតុលាការអីទេដើម្បីកាត់ទោសអ្នកអស់នោះដែរទេ អ្នកធំៗនឹងណា៎? ព្រោះថាមនុស្សស្លាប់រាប់លាននាក់ ប្រជាជនក្នុងភូមិសឹងតែបាត់បង់បងប្អូន មួយគ្រួសារបាត់ម្នាក់ តើគិតថាគួរតែកាត់ទោសអ្នកអស់នឹង ទេ ដើម្បីផ្តល់យុត្តិធម៌ឲ្យដល់ប្រជាជន?

ស្រល់ៈ មកនេះមិនបាច់តែខ្ញុំទេ សូម្បីតែប្រជាជននឹងស្តាប់មើលទៅគឺថាបន់ឲ្យតែកាត់ទោសខ្មែរក្រហមរូតរះឆាប់ៗនឹង ។

វីរៈ អញ្ចឹងទាំងពូទាំងប្រជាជនទាំងអស់ រាល់ថ្ងៃគាត់ទន្ទឹមមើល ចាំមើលថាតុលាការកើតមានដែរ ឬអត់?

ស្រល់ៈ ចាំមើលថាកើតមិនកើត បើខ្មែរក្រហម បើប៉ុល ពតសម្លាប់ប៉ុណ្ណឹងហើយ ថាតើយើងកាត់កើតមិនកើត ។

វីរៈ ក្នុងគោលបំណងអីគេដែលគិតថាឲ្យកាត់នឹង? ដូចឥឡូវគំនិតពូផ្ទាល់ ពូថាចង់ឲ្យកាត់នឹងដោយសារមូលហេតុអីគេបានពូចង់ឲ្យកាត់អញ្ចឹង វាមានប្រយោជន៍អីខ្លះដល់ពូ ដល់ប្រទេសជាតិ ដល់ប្រជាជនទាំងមូល?

ស្រល់ៈ បញ្ហារឿងថាឲ្យកាត់ទោសខ្មែរក្រហមនឹង គឺដើម្បីថាឲ្យប្រជាជនយើងគាត់អស់ចម្ងល់គាត់ថា បំណាច់ថាសម្លាប់មនុស្សអស់រាប់លានមិនឈ្នះហើយ ហើយមិនឃើញកាត់មិនឃើញអី អានឹងដល់យូរៗគាត់លែងជឿយើងហើយ ហើយបើយើងថាកាត់ហើយ កាត់ឲ្យឃើញជាក់ស្តែងហ្នឹងមើល អានឹងគាត់មានជំនឿលើយើង ថាអ្នកដឹកនាំយើងនិយាយម៉ាត់ណាគឺម៉ាត់នឹងច្បាស់លាស់អញ្ចឹងហ្នឹង ។

វីរៈ សួរថាការកាត់ទោសហើយនឹង អឺការកាត់ទោសនឹងវាអាចផ្តល់យុត្តធម៌ដល់បងប្អូនដែលបាត់បង់ទៅនឹង?

ស្រល់ៈ ដល់បងប្អូនយើងស្លាប់ទៅនោះ ។

វីរៈ វាអាចផ្តល់យុត្តិធម៌ដែរហ៎?

ស្រល់ៈ បាទ ។

វីរៈ ហើយគិតថាការកាត់អញ្ចឹង វាជាគំរូមួយទេសម្រាប់ទៅថ្ងៃក្រោយហ៎ កុំឲ្យកើតមានអំពើនឹងឡើងវិញទៀតទេ?

ស្រល់ៈ អានឹងអញ្ចឹងហើយ ដើម្បីកុំឲ្យទៅថ្ងៃមុខទៀតមានគំរូអញ្ចឹង ប្រជាជនយើងម្នាក់ៗគិតអញ្ចឹងដែរនឹង ។

វីរៈ ដូចថាបើសិនជាយើងកាត់ទោស ប្រជាជនរំសាយចិត្តខ្លះទេ? កាត់ទោសនឹង បើសិនជាកាត់ទោសនឹងអាចរំសាយចិត្តខឹងទេ បាត់ខឹងទេ?

ស្រល់ៈ តែកាត់ទោសសម្រេចចប់ហើយ ទាំងគេទាំងខ្ញុំរំសាយហើយ លែងខឹងហើយ លែងហើយ ។

វីរៈ អញ្ចឹង បើខ្ញុំយករឿងរាវរបស់ពូនេះទៅសរសេរជាអត្ថបទ ជារឿង ដូចថាជាសៀវភៅជាអីដើម្បីផ្សព្វផ្សាយដើម្បីឲ្យក្មេងៗបានដឹងអី ពូពេញចិត្តឲ្យយកទៅផ្សព្វផ្សាយដែរឬអត់ទេ?

ស្រល់ៈ មានអី អត់មានទៅថាអន់ចិត្តអន់អីទេ ពេញចិត្តហើយគាំទ្រអស់នឹង ខ្ញុំមិនគិតខ្លាចទេ ព្រោះខ្ញុំនិយាយអញ្ចឹងទៅ ត្បិតខ្ញុំនៅកន្លែងនឹងដែរ ខ្ញុំនិយាយទៅខ្លាច ខ្ញុំអត់មានខ្លាចទេ ។

វីរៈ ពូអត់មានខ្លាចទេហ៎?

ស្រល់ៈ អត់ ។

វីរៈ អញ្ចឹង ពូមានអីចង់បញ្ជាក់បន្ថែម នូវអីដែលខ្ញុំអត់បានសួរនាំពូទៀតទេ?

ស្រល់ៈ អត់ ។

វីរៈ ហើយខ្ញុំបញ្ជាក់ពូចុងក្រោយថា ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយកន្លែងខ្ញុំធ្វើការហ្នឹងដូចថាមានគោលបំនងមួយដែរ...... ។

**ចប់**